ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ ២ ត្រីមាសទី២ ឆ្នាំ២០១៩

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ECOSOCC




កសវ

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577    (855) 012 912 009



<u>**ប្រសាសន៍ពេជ្រ**</u>

" សន្តិភាពនិងការអភិវឌ្ឍនៅជាមួយគ្នាជានិច្ច មានសន្តិភាពទើបមានការអភិវឌ្ឍ មានការអភិវឌ្ឍទើបរក្សាបានសន្តិភាព។ "

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

( ឆ្នាំ២០០៦ )

## I- អារម្ភកថា

ព្រឹត្តិបត្រពត៌មានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) ហៅកាត់ជាភាសាអង់គ្លេស ECOSOCC មានគោលបំណងធ្វើជាស្ពាននាំព័ត៌មានដ៏ប្រាកដក្នុងផ្លូវសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងព្រឹត្តិការណ៍ទូទៅ ជូនដល់អ្នកអាន និងអ្នកសិក្សាស្រាវជ្រាវ បានដឹង និងស្វែងយល់ឲ្យបានប្រាកដប្រជា។ ប្រជាពលរដ្ឋកម្ពុជា ក៏ដូចជាប្រជាពលរដ្ឋនៅលើពិភពលោកដែរ គឺតែងមានសេចក្តីខ្វល់ខ្វាយចំពោះបញ្ហាប្រទេសរបស់ខ្លួន ហើយច្រើនតែបានទទួលព័ត៌មានដែលឃ្លាតពីសេចក្តីពិត បណ្តាលឲ្យមានក្តីសៅហ្មងដល់សទ្ធា និងសេចក្តីស្នេហាជាតិដែលខ្លួនមានចំពោះប្រទេសអំពីការវិវត្តលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

ហេតុនេះក្នុងតួនាទីជាយន្តការអមទីស្តីការគណៈរដ្ឋមន្ត្រី ក.ស.វ. មានភារកិច្ចចម្បងក្នុងការបំពេញចំណង់ដ៏ឧត្តមនេះ ជូនដល់អ្នកអាន និងអ្នកសិក្សាស្រាវជ្រាវ ដើម្បីបានជាទុនក្នុងការត្រិះរិះពិចារណានូវបញ្ហាជាតិឲ្យបានគ្រប់ជ្រុងជ្រោយ។ ព្រឹត្តិបត្រនេះ ជាមធ្យោបាយមួយផ្សព្វផ្សាយដើម្បីលើកស្ទួយលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌យើងឲ្យកាន់តែត្រដែតឡើង ព្រមទាំងពង្រីកពុទ្ធិឲ្យបានជ្រៅជ្រះ រួមចំណែកអភិវឌ្ឍន៍ស្រុកទេសឲ្យថ្កុំថ្កើងដូចសម័យចក្រភពអង្គរ។

ព្រឹត្តិបត្រនេះធ្វើការវិភាគ និងផ្តល់ព័ត៌មានពីទីងងឹតមកទីភ្លឺវិញ ដោយឈរលើមូលដ្ឋានវិទ្យាសាស្ត្រ។ បទពិសោធន៍ក្នុងប្រវត្តិសាស្ត្រកម្ពុជា បានបញ្ជាក់ម្តងហើយម្តងទៀតថា នៅពេលប្រទេសស្ថិតក្នុងសុខសន្តិភាព ប្រជាពលរដ្ឋរស់ក្នុងភាពសុខសាន្ត គឺប្រទេសជាតិមានការអភិវឌ្ឍ។

បច្ចុប្បន្ននេះ កម្ពុជាក្រោមការដឹកនាំរបស់ប្រមុខរាជរដ្ឋាភិបាល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រៀបដូចជាយុវតីស្ថិតក្នុងវ័យជំទង់ ដែលពីម្សិលមិញគ្រាន់តែជាក្មេងស្រីម្នាក់ប៉ុណ្ណោះ។ ប៉ុន្តែថ្ងៃនេះ ស្រាប់តែប្រែក្លាយជាអប្សរទៅវិញ ម្សិលមិញបិទបាំងមុខមាត់ត្រូវគេបំភ្លេចចោល ថ្ងៃនេះស្រាប់តែប្រែក្លាយជាស្រស់ស្អាតទាក់ទាញចំណាប់អារម្មណ៍អ្នកចង់ចែចូវមកពីគ្រប់តំបន់លើពិភពលោក។

ក.ស.វ. សូមជូនព្រឹត្តិបត្រនេះដល់អ្នកអាន និងអ្នកសិក្សាស្រាវជ្រាវ ដើម្បីជាមធ្យោបាយមួយសម្រាប់ទទួលព័ត៌មានប្រកបដោយភាពច្បាស់លាស់ និងចម្រើនវិជ្ជាក្នុងការស្វែងយល់អំពីការវិវត្តលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌៕

# ទស្សនាទាននៃការអភិវឌ្ឍន៍ប្រភពថាមពលកកើតឡើងវិញនៅកម្ពុជា ស្ថានីយវារីអគ្គិសនី និង ស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យ

*ដោយ បណ្ឌិត អ៊ុច ចេងសេង*

អត្ថបទនេះមានគោលបំណងបង្ហាញផលប្រយោជន៍នៃថាមពលកកើតឡើងវិញក្នុងការកាត់បន្ថយផលប៉ះពាល់ដោយកំណើនកម្តៅផែនដី និងឆ្លើយទៅនឹងសំណួរថា ហេតុអ្វីបានជាស្ថានីយវារីអគ្គិសនីមិនផលិតអគ្គិសនីនៅរដូវប្រាំង។

ពីមួយឆ្នាំទៅមួយឆ្នាំ កំណើនកម្តៅផែនដីកាន់តែកើនឡើង បង្ករឡើងដោយការផលិតថាមពលសម្រាប់ផ្គត់ផ្គង់កំណើនប្រជាជនលើពិភពលោក។ អ្នកវិទ្យាសាស្ត្រទទួលស្គាល់ថា កម្តៅក្នុងរដូវប្រាំងឆ្នាំ២០១៩ នេះក្តៅជាងកម្តៅពីឆ្នាំមុនៗ។ មានដំបន់ខ្លះនៅទ្វីបអាហ្វ្រិកមិនដែលស្គាល់ភ្លៀងមួយដំណក់ក្នុង រយៈពេល ៤ ឬ ៥ឆ្នាំជាប់គ្នា។ ប្រជាជននាំគ្នារត់ចោលទីកន្លែងកំណើត ព្រោះតែរស់នៅលែងកើត។ ក្នុងដំបន់ផ្សេងទៀតមិនត្រឹមតែដីមិនមែនជាអាងទឹកត្រូវបែកក្រហែងទេ ដីដែលធ្លាប់តែជាអាងទឹកក៏ត្រូវបែកក្រហែងដែរ ព្រោះគ្មានភ្លៀងធ្លាក់ចូលអាង។

អ្នកវិទ្យាសាស្ត្របានពន្យល់ថា នៅពេលកកើតផែនដីប្រមាណ ៥ពាន់លានឆ្នាំមុន នៅក្នុងស្រទាប់បរិយាកាសផែនដី មានតែឧស្ម័នកាបូនិក($CO_2$) អាហ្សូត(Nitrogen) និងចំហាយទឹក($H_2O$)។ ក្នុងអំឡុងពេលច្រើនលានឆ្នាំក្រោយមក កម្តៅផែនដីចុះថយបន្តិចម្តងៗ ចំហាយទឹកក្នុងលំហអាកាសបានប្រមូលផ្តុំជាទឹកសមុទ្រជុំវិញផែនដី។ ពពួកស្លែ សារាយ រុក្ខជាតិដែលកកើតឡើងដោយប្រើប្រាស់សំយោគពន្លឺថ្ងៃ (Photosyntheses) ដើម្បីផលិតជាជាតិស្ករ(Glucose) និងទឹកបានស្រូបយកឧស្ម័នកាបូនិក ពីស្រទាប់បរិយាកាស។ ក្នុងរយៈពេលប្រហែល ២០លានឆ្នាំ បរិមាណឧស្ម័នកាបូនិក បានបន្ថយមកនៅត្រឹម ៣០០ ppm (ម៉ូលេគុលក្នុង១លានម៉ូលេគុលខ្យល់)[១]។

ក្នុងរយៈពេលជាង ១០០ឆ្នាំចុងក្រោយ ការវិវត្តនៃវិស័យឧស្សាហកម្មបាននាំឲ្យមនុស្សជីកកកាយយកធ្យូងថ្មពីក្នុងដី និងបូមប្រេងកាតពីក្នុងដីនិងសមុទ្រមកបំពេញតម្រូវការថាមពល។ ការដុតធ្យូងថ្ម និងប្រេងកាតដើម្បីផលិតថាមពលនេះបានបំភាយសារធាតុកាបោនដែលរក្សាកប់ទុកក្នុងដី និងបាតសមុទ្រជាច្រើនលានឆ្នាំមុន ឲ្យហោះហើរអណ្តែតក្នុងស្រទាប់បរិយាកាសជុំវិញផែនដីវិញ ដែលជាមូលហេតុនាំឲ្យមានកំណើនកម្តៅពិភពលោក ។ ក្នុងឆ្នាំ២០១៥ កម្រិតបរិមាណឧស្ម័នកាបូនិក នៅក្នុង អាកាសកើនលើស 400 ppm ជាកម្រិតដែលកើនលើស 40% នៃកម្រិត មុនការវិវត្តឧស្សាហកម្មដែលស្មើនឹង 280 ppm ។ កម្រិតបរិមាណឧស្ម័នកាបូនិក 400 ppm មិនធ្លាប់មានទេក្នុងរយៈពេលច្រើនលានឆ្នាំចុងក្រោយ។

អ្នកវិទ្យាសាស្ត្រយល់ឃើញថា ការកាត់បន្ថយការបំភាយឧស្ម័នកាបូនិកទៅក្នុងបរិយាកាស គឺជាការថែរក្សាបរិយាកាសជុំវិញផែនដីឲ្យមានកម្តៅដែលមនុស្សជំនាន់ក្រោយអាចរស់នៅកើត។ ជម្រើសដែលប្រទេសមួយចំនួនបានអនុវត្តរួចមកហើយក្នុងការផលិតថាមពលដោយមិនបំភាយឧស្ម័នកាបូនិកទៅក្នុងអាកាសគឺការប្រើប្រាស់ថាមពលកកើតឡើងវិញ។ ប្រភពទាំងនោះមានកម្តៅក្នុងដី(Geothermal) មាននៅក្នុងប្រទេសដែលមានភ្នំភ្លើងច្រើន ថាមពលខ្យល់ ថាមពលទឹកសមុទ្រជោរនាច ថាមពលវារីអគ្គិសនី និងថាមពលអគ្គិសនីពន្លឺព្រះអាទិត្យ ។ បច្ចុប្បន្ន នៅប្រទេសកម្ពុជាមានតែស្ថានីយវារីអគ្គិសនី និងស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យ

ដែលដំណើរការផលិតអគ្គិសនី។ តើស្ថានីយវារីអគ្គិសនី និងស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យដំណើរការផលិតអគ្គិសនី ដូចម្តេចដែរ?

### ក- ស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យ

ក្នុងឆ្នាំ១៨៧៦ William Grylls Adams បានរកឃើញថា បន្ទះ (selenium) អាចផលិតអគ្គិសនីបាននៅពេលទទួលពន្លឺព្រះអាទិត្យ។ ក្នុងឆ្នាំ១៩៥៣ Calvin Fuller, Gerald Pearson, and Daryl រកឃើញថា បន្ទះស៊ីលីកូនសូឡា(silicon solar cell) អាចផលិតអគ្គិសនីសម្រាប់ដំណើរការឧបករណ៍អគ្គិសនី។ ក្នុងឆ្នាំ១៩៥៦ បន្ទះអគ្គិសនីសូឡាផលិតដំបូង 1w មានតម្លៃ 300$។ បច្ចុប្បន្ន បន្ទះអគ្គិសនីសូឡា 1w មានតម្លៃតិចជាង 1$ [២]។

ដោយសារតម្លៃបន្ទះសូឡាចុះថោក អគ្គិសនីដែលផលិតដោយពន្លឺព្រះអាទិត្យអាចប្រកួតប្រជែងជាមួយអគ្គិសនីដែលផលិតដោយប្រភពថាមពលដទៃទៀត។ ប៉ុន្តែចំណុចខ្សោយនៃស្ថានីយអគ្គិសនីពន្លឺព្រះ-អាទិត្យ គឺមិនអាចផលិតអគ្គិសនីនៅពេលយប់បាន ហើយបើសិនជាចង់រក្សាថាមពលដែលផលិតបាននោះមកប្រើប្រាស់ពេលយប់ លុះត្រាតែមានអាគុយសម្រាប់រក្សាទុក ដែលធ្វើឲ្យតម្លៃអគ្គិសនីសូឡាសម្រាប់ប្រើពេលយប់មានតម្លៃថ្លៃ។ ចំណុចខ្សោយមួយទៀតគឺ ស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យ អាចផលិតអគ្គិសនីបានតិចនៅពេលមានពពកច្រើន។

ក្នុងករណីស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យមិនដំណើរការផលិតអគ្គិសនីនៅពេលយប់ និងផលិតបានតិចនៅពេលមានពពកច្រើន ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីសរុបត្រូវមានស្ថានីយអគ្គិសនីដែលដំណើរការភ្លាមៗដើម្បីប៉ះប៉ូវតម្រូវការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់តាមតម្រូវការឡើងវិញ ដើម្បីជៀសវាងកុំឲ្យមានការផ្តាច់ការផ្គត់ផ្គង់ចរន្តអគ្គិសនី។ ស្ថានីយអគ្គិសនីដែលអាចដំណើរការភ្លាមៗដើម្បីប៉ះប៉ូវតម្រូវការ គឺស្ថានីយវារីអគ្គិសនី និងស្ថានីយអគ្គិសនីប្រើប្រេងឬឧស្ម័ន ព្រោះស្ថានីយអគ្គិសនីយបរមាណូនិងប្រើធ្យូងថ្មត្រូវការពេលវេលាដើម្បីកំដៅឡើ។

### ខ- ស្ថានីយវារីអគ្គិសនី

ស្ថានីយវារីអគ្គិសនីត្រូវបានសាងសង់ដើម្បីបម្រើគោលបំណងច្រើន ដូចជា ផ្គត់ផ្គង់អគ្គិសនី គ្រប់គ្រងទឹកជំនន់ បង្ហូរទឹកស្រោចស្រពដំណាំ នេសាទ នាវាចរណ៍ និងទេសចរណ៍។ ផលប្រយោជន៍លម្អិតនៃស្ថានីយវារីអគ្គិសនី នឹងមានរៀបរាប់លម្អិតនៅក្នុងព្រឹត្តិបត្រព័ត៌មានលើកក្រោយ។

ថាមពលវារីអគ្គិសនីក៏មានប្រភពពីព្រះអាទិត្យដែរ។ កំដៅព្រះអាទិត្យបានបំភាយចំហាយទឹកពីផ្ទៃដីបឹង ស្ទឹង ទន្លេ និងសមុទ្រទៅក្នុងអាកាស។ ចំហាយទឹកប៉ះខ្យល់ត្រជាក់ប្រមូលផ្តុំជាភ្លៀងធ្លាក់មកផែនដីវិញ។ ការទប់ទឹកនៅទីខ្ពស់ដើម្បីបង្ហូរមកទីទាបបង្កើតថាមពលប៉ូតង់ស្យែល ដែលបង្ហូរមកដល់ទួរប៊ីននៅស្ថានីយខាងក្រោម បង្កើតជាថាមពលស៊ីណេទិក ក្រោយមកជាថាមពលម៉េកានិក ដើម្បីបង្វិលទួរប៊ីននិងឌីណាម៉ូ ឬយ៉េណេរ៉ាទ័រ(Generator)។









យោងតាមទិន្នន័យធារទឹកមធ្យមប្រចាំខែនៅស្ទឹងទាំង៣ និងនៅតាមដងទន្លេមេគង្គ ទាំងនៅប្រទេសថៃ ឡាវ និង កម្ពុជា Chieng Saen, Luong Prabang , Vientiane , Nakhon Phanon , Mukdahan, Pakse , Kratie ម៉ូដែលបរិមាណធារទឹកមធ្យមប្រចាំខែដែលច្រើនមានតែនៅក្នុងខែ ៧ ៨ ៩ និង ១០។ បរិមាណធារទឹកមធ្យមប្រចាំខែនៅក្នុងខែទាំង៤ នេះ ច្រើនជាងបរិមាណធារទឹកមធ្យមប្រចាំខែនៅរដូវប្រាំងពី ៥០ រហូតជាង ១០០ដង។ ក្នុងការសាងសង់ស្ថានីយវារីអគ្គិសនី ចំណាយថវិកាមួយផ្នែកធំទៅលើការសាងសង់ទំនប់សម្រាប់បង្កើតអាងទឹក។ ដើម្បីផលិតអគ្គិសនីបានតម្លៃទាប និងទទួលបានចំណូលមកវិញឲ្យបានច្រើន ស្ថានីយវារីអគ្គិសនីត្រូវផលិតអគ្គិសនីអោយបានច្រើន ហេតុនេះទើបមានការដំឡើងម៉ាស៊ីនអគ្គិសនីច្រើនគ្រឿង ឬម៉ាស៊ីនអគ្គិសនីអានុភាពធំ សម្រាប់ផលិតអគ្គិសនីឲ្យបានច្រើនក្នុងខែទាំង៤ នេះ។

ដើម្បីមានបរិមាណទឹកសម្រាប់ដំណើរការស្ថានីយវារីអគ្គិសនីនៅរដូវប្រាំង អ្នកគ្រប់គ្រងស្ថានីយវារី-អគ្គិសនី ត្រូវថែរក្សាបរិមាណទឹករដូវវស្សាមួយផ្នែកនៅក្នុងអាងទឹក។ ប៉ុន្តែ ទោះជាមានការព្យាយាមដំឡើងម៉ាស៊ីនអគ្គិសនីច្រើនគ្រឿង ឬម៉ាស៊ីនអគ្គិសនីអានុភាពធំសម្រាប់ផលិតអគ្គិសនីឲ្យអស់លទ្ធភាព និងអាងទឹកទំហំធំសម្រាប់រក្សាទឹកទុកប្រើខែប្រាំងក៏ដោយ ក៏នៅតែមានបរិមាណទឹកដែលត្រូវបង្ហូរចោលតាមសំណាង់បង្ហៀរ( Spillway ) ដោយមិនបានផលិតអគ្គិសនីដែរ។ ការបង្ហូរទឹកតាមសំណាង់បង្ហៀរព្រោះសមត្ថភាពចំណុះអាងទឹកមិនអាចរក្សាទុកទឹកបាន និងទោះបីជាម៉ាស៊ីនវារីអគ្គិសនីដំណើរការទាំងអស់ក្តី កើតមានឡើងនៅពេលមានទឹកជំនន់បង្កដោយព្យុះ។





រូបខាងឆ្វេង ជារូបបង្ហូរទឹកជំនន់ចេញពីទំនប់ Three Gorges លើដងទន្លេយ៉ាងសេ ប្រទេសចិន និងខាងស្តាំ ជារូបបង្ហូរទឹកជំនន់ពីអាងទឹកកំចាយ ខេត្តកំពត។ មិនមានទំនប់ទឹកណាមួយលើពិភពលោកអាចស្តុកទឹកជំនន់រដូវវស្សាបានទាំងអស់ឡើយ ទោះបីទំនប់ទឹក Three Gorges ដែលជាទំនប់ទឹកដ៏ធំមួយលើពិភពលោក ដែលត្រូវជន្លៀសប្រជាជនចំនួន 1,2 លាននាក់ ដើម្បីទុកផ្ទៃដីបង្កើតអាងទឹក 1050 $Km^2$ ។

ដូចនេះ បរិមាណទឹកក្នុងរដូវវស្សានៅទីតាំងស្ថានីយវារីអគ្គិសនីត្រូវបានចែកជាបីផ្នែក ទី១ ដំណើរការទួរប៊ីនសម្រាប់ផលិតអគ្គិសនី ទី២ រក្សាទុកក្នុងអាងសម្រាប់ប្រើប្រាស់នៅរដូវប្រាំង និងទី៣ បង្ហូរចោលតាមសំណាង់បង្ហៀរ។




ជាទូទៅ អាងទឹកនៃស្ថានីយវារីអគ្គិសនី ត្រូវចាប់ផ្តើមរក្សាទឹកទុកនៅខែ៦ ដើម្បីបង្កើនកម្ពស់កម្លាំងទឹកសម្រាប់ផលិតអគ្គិសនីបានច្រើន។ ការរក្សាទឹកមិនឲ្យហូរនេះ ផ្ទុយពីតម្រូវការឲ្យមានទឹកហូរច្រើន សម្រាប់បម្លាស់ទីត្រីពង។ ការសម្របសម្រួលរកផលប្រយោជន៍រួមមួយត្រូវការពេលវេលាដើម្បីសិក្សាលម្អិតរួម។

ម៉ាស៊ីនវារីអគ្គិសនីនិមួយៗជាសំណុំនៃទួរប៊ីន យេណេរ៉ាទ័រ បំពង់ទឹក ទ្វារទឹក និងឧបករណ៍ជំនួយជាច្រើនទៀត។ ក្នុងរដូវវស្សា សំណុំនៃម៉ាស៊ីនវារីអគ្គិសនីនិមួយៗនេះត្រូវដំណើរការ ២៤ម៉ោងក្នុងមួយថ្ងៃ រយៈពេល ៤ ទៅ ៦ខែ ។ ក្នុងរយៈពេលនេះ ផ្នែកណាមួយនៃសំណុំទួរប៊ីន យេណេរ៉ាទ័រ បំពង់ទឹក ទ្វារទឹក និងឧបករណ៍ជំនួយមិនដំណើរការ ម៉ាស៊ីនវារីអគ្គិសនីនោះនឹងមិនដំណើរការ ហើយត្រូវធ្វើការជួសជុលតូច (Minor Repair) ហើយចំនួនម៉ាស៊ីនវារីអគ្គិសនីដែលត្រូវការជួសជុលតូចនោះ មានប្រហែលពី ៥% ទៅ ១០%។ ក្នុងរដូវប្រាំង ម៉ាស៊ីនវារីអគ្គិសនីដែលដំណើរការពេញរយៈពេល ៤ ទៅ ៦ខែ ត្រូវការផ្អាកដំណើរការ ដើម្បីធ្វើការជួសជុលធំ(Major Repair)។ ចំនួនម៉ាស៊ីនដែលផ្អាកដំណើរការដើម្បីធ្វើការជួសជុលធំអាចមានពី ៣០% ទៅ ៥០%។ នៅចុងរដូវប្រាំង ម៉ាស៊ីនវារីអគ្គិសនីទាំងអស់ត្រូវបានធ្វើការជួសជុលធំរួច ដើម្បីត្រៀមដំណើរការពេញមួយរដូវវស្សាខាងមុខ។

លក្ខណៈពិសេសរបស់ស្ថានីយវារីអគ្គិសនី គឺការសន្សំទឹកទុកសម្រាប់ប្រើប្រាស់។ ឧទាហរណ៍ស្ថានីយវារីអគ្គិសនីអាចបញ្ចេញទឹកពីអាងដើម្បីដំណើរការម៉ាស៊ីន ៥គ្រឿងក្នុងរយៈពេល ២៤ម៉ោង ប៉ុន្តែស្ថានីយវារីអគ្គិសនីនោះ អាចមិនដំណើរការក្នុងរយៈពេល ១២ម៉ោង ដោយរក្សាទឹកនោះទុកដើម្បីដំណើរការម៉ាស៊ីន ១០គ្រឿងក្នុងរយៈពេល ១២ម៉ោងវិញ។

លក្ខណៈពិសេសខាងលើនេះ អាចជួយសម្រួលដល់ការផ្គត់ផ្គង់អគ្គិសនីដល់ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីដែលតម្រូវការអគ្គិសនីមានការប្រែប្រួលកើនឡើងនៅពេលយប់ពីម៉ោង ៦ ដល់ ១១យប់(ម៉ោង Peak) និងនៅពេលថ្ងៃដោយដំណើរការរោងចក្រ។ ចន្លោះពេលដែលតម្រូវការអគ្គិសនីធ្លាក់ចុះ ម៉ាស៊ីនវារីអគ្គិសនីអាចផ្អាកដំណើរការ និងសន្សំទឹកទុកសម្រាប់ដំណើរការពេលតម្រូវការអគ្គិសនីកើនឡើង(ម៉ោង Peak )។

ធម្មជាតិបង្កើតឲ្យមានរដូវវស្សានិងរដូវប្រាំង។ ភ្លៀងនៅរដូវវស្សា ថ្ងៃក្តៅនៅរដូវប្រាំង។ ស្ថានីយវារីអគ្គិសនីផលិតអគ្គិសនីច្រើននៅរដូវវស្សា ស្ថានីយពន្លឺព្រះអាទិត្យផលិតអគ្គិសនីច្រើននៅរដូវប្រាំង។ ស្ថានីយទាំងពីរផលិតអគ្គិសនីបំពេញគ្នាទៅវិញទៅមក ដោយលក្ខណៈធម្មជាតិ[៣]៕

(១) https://www.bbc.com/news/amp/science-environment-41671770

(២) https://www.experience.com/advice/careers/ideas/the-history-of-solar-power/

(៣) អត្ថបទនេះមានតនៅលេខក្រោយទៀត។

## ១- សេចក្តីព្រាងគោលនយោបាយជាតិស្តីពី

### ការសិក្សាពេញមួយជីវិត



បញ្ញត្តិនៃ ” ការសិក្សាពេញមួយជីវិត ” ឆ្នាំ ១៩៧២ ជាបញ្ញត្តិគោលមួយដែលត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយអប់រំរបស់ប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍជាច្រើន។ អនុលោមតាមបញ្ញត្តិនេះ ការងារជាច្រើនត្រូវបានប្រទេសនីមួយៗដាក់ចេញអនុវត្ត បើទោះបីជាមានជួបបញ្ហាប្រឈមមួយចំនួន ទៅតាមករណីប្រទេសផ្សេងៗគ្នាក៏ដោយ។ បន្តពីស្មារតីនេះ ការអប់រំសម្រាប់ទាំងអស់គ្នាដែលជាចលនាពិភពលោក ដើម្បីឲ្យកុមារ យុវជន និងជនពេញវ័យគ្រប់រូប មានសិទ្ធិទទួលបានប្រយោជន៍ពីការអប់រំយ៉ាងពេញលេញ និងប្រកបដោយគុណភាព ត្រូវបានបង្កើតឡើងឆ្នាំ១៩៩០ ហើយត្រូវបានវាយតម្លៃ និងពិនិត្យឡើងវិញនៅឆ្នាំ២០០០។

ឈានចូលស.វ.ទី២១នេះ ការសិក្សាពេញមួយជីវិតបានក្លាយជាប្រធានបទដ៏សំខាន់សម្រាប់ការអប់រំ ហើយក៏ជាឧបករណ៍ដែលមានប្រយោជន៍សម្រាប់ឲ្យប្រជាជនទទួលបានសិទ្ធិសេរីភាព ភាពសប្បាយរីករាយ និងឆ្លើយតបទៅនឹងតម្រូវការនៃទីផ្សារការងារ។ ព្រមជាមួយនេះ ការសិក្សាពេញមួយជីវិត ក៏បានក្លាយជាសមាសភាគសំខាន់នៃក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ឆ្នាំ២០៣០ ដែល “ធានាឲ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា” អ៊ីនឈន់ សាធារណរដ្ឋកូរ៉េ។

ប្រវត្តិនៃការអភិវឌ្ឍវិស័យអប់រំនៅប្រទេសកម្ពុជាបានបង្ហាញថា តាមរយៈក្រសួងអប់រំ យុវជន និងកីឡា រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងផ្តល់ឱកាសតាមគ្រប់រូបភាពដល់ប្រជាជនកម្ពុជាគ្រប់រូប ដើម្បីទទួលបានការអប់រំទាំងអស់គ្នា ដោយបានបើកយុទ្ធនាការរំដោះគ្រោះមិនចេះអក្សរនិងគ្រោះភ្លេចអក្សរ តាមពាក្យស្លោក “អ្នកចេះបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះ” (ទសវត្សឆ្នាំ១៩៨០) និងរៀនហើយរៀនទៀត រៀនមិនចេះចប់(ទសវត្សឆ្នាំ១៩៩០) និងបានដាក់ចេញនូវគោលនយោបាយអប់រំក្រៅប្រព័ន្ធឆ្នាំ២០០២ ព្រមទាំងកសាងបានច្បាប់ស្តីពីការអប់រំ(ឆ្នាំ២០០៧)។

តាមមាត្រា៦៥ នៃរដ្ឋធម្មនុញ្ញដែលចែងថា “រដ្ឋត្រូវការពារនិងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឲ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប” និងមាត្រា៦៦ “ រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ

និងឯកភាពនៅទូទាំងប្រទេស ដែលធានាឲ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើគ្នាក្នុងការកសាងជីវិត” និងដើម្បីដោះស្រាយបញ្ហាប្រឈមមួយចំនួន ព្រមទាំងឆ្លើយតបទៅនឹងចក្ខុវិស័យនៃបញ្ញត្តិខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានកសាងគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត សំដៅបង្កើនការអភិវឌ្ឍធនធានមនុស្សប្រកបដោយសក្តានុពល ឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ ដែលបានកំណត់។ គោលនយោបាយនេះ ជាយន្តការប្រទាក់ក្រឡាដែលទាមទារឲ្យមានការខិតខំប្រឹងប្រែងរួមគ្នាតាមគ្រប់ទម្រង់នៃការសិក្សា (ការសិក្សាក្នុងប្រព័ន្ធ ការសិក្សាក្រៅប្រព័ន្ធ ការសិក្សាមិនផ្លូវការ) ពីគ្រប់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីផ្តល់ឱកាសច្រើនបំផុតទៅដល់អ្នកសិក្សាគ្រប់វ័យ ពិសេសក្រុមជនបាត់បង់ឱកាស។

សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត ត្រូវបានដាក់ឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសនៅទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ដឹកនាំដោយសហប្រធាន ឯកឧត្តម **ឆយ អួន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ឯកឧត្តម **ស៊ា ម៉ៅ** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ដោយមានឯកឧត្តម **ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា តំណាងក្រសួងសាមី ជាអ្នកការពារសេចក្តីព្រាង។ កិច្ចប្រជុំបានយកចិត្តទុកដាក់ពិភាក្សាលើយុទ្ធសាស្ត្រ(ចំនួន១១) ដែលក្រសួងបានលើកឡើង ដើម្បីឲ្យគោលនយោបាយនេះទទួលបានលទ្ធផលល្អនៅពេលដាក់ចេញអនុវត្ត៕

# ២- សេចក្តីព្រាងច្បាប់ស្តីពី

## ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ( Law on E-Commerce )



តាមរយៈកិច្ចព្រមព្រៀងស្តីពី E-ASEAN ជាមួយនឹងការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះអង្គការពាណិជ្ជកម្មពិភពលោក (WTO) រួមជាមួយនឹងបណ្តាប្រទេសជាសមាជិកអាស៊ាន រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចបាននូវការប្តេជ្ញាចិត្តក្រោមក្របខណ្ឌ E-ASEAN តាមរយៈការរៀបចំ និងការអនុម័តច្បាប់ ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (Law on E-Commerce)។

ក្រសួងពាណិជ្ជកម្មបានរៀបចំច្បាប់នេះឡើងដោយផ្អែកលើច្បាប់ UNCITRAL ច្បាប់របស់បណ្តាប្រទេសក្នុងតំបន់អាស៊ាន និងបានបញ្ចូលបទប្បញ្ញត្តិមួយចំនួនទាក់ទងនឹងការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក សកម្មភាពនិងប្រតិបត្តិការរបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក និងកិច្ចការពារអ្នកប្រើប្រាស់លើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានសមាសភាពចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធរួមមាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ធនាគារជាតិនៃកម្ពុជា ក្រសួងយុត្តិធម៌ គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) និងអ្នកជំនាញការច្បាប់មកពីក្រុមមេធាវី DFDL។ ច្បាប់នេះមាន១១ជំពូក និង៥៨មាត្រា។

ច្បាប់នេះមានគោលបំណងគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអន្តរជាតិ ដើម្បីបង្កើតភាពប្រាកដប្រជាផ្នែកគតិយុត្តក្នុងប្រតិបត្តិការផ្នែករដ្ឋប្បវេណី និងផ្នែកពាណិជ្ជកម្មដែលទាក់ទងទៅនឹងទំនាក់ទំនងអេឡិចត្រូនិក ដោយផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

លក្ខណៈពិសេសរួមរបស់ច្បាប់នេះ គឺទទួលស្គាល់ទំនាក់ទំនងរបស់ភាគីពាណិជ្ជកម្ម ដោយមិនចាំបាច់ប្រើប្រាស់លិខិតស្នាមជាក្រដាសដែលជាទម្លាប់ប្រើតាមកិច្ចសន្យាទូទៅ និងប្រើប្រាស់កន្លងមក។ ម្យ៉ាងទៀត ជាវិធានមួយសម្រាប់បង្កើតកិច្ចសន្យា និងធានាសុពលភាពនៃកិច្ចសន្យាទាំងឡាយដែលភាគីបានចុះកិច្ចព្រមព្រៀងតាមប្រព័ន្ធអេឡិចត្រូនិច ព្រមទាំងរក្សាទិន្នន័យសារអេឡិចត្រូនិក ក្នុងគោលបំណងទទួលស្គាល់អ្នកទទួលសារអេឡិចត្រូនិក និងកំណត់ពេលវេលា និងទីកន្លែងរបស់អ្នកផ្ញើ និងអ្នកទទួលសារអេឡិចត្រូនិក។

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានសារប្រយោជន៍ សម្រួលដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទាំងក្នុងប្រទេស និងអន្តរជាតិដោយលុបបំបាត់របាំងនានា និងបង្កើតភាពប្រាកដប្រជាផ្លូវច្បាប់ ព្រមទាំងបង្កើនទំនុកចិត្តរបស់ពាណិជ្ជករ និងអ្នកប្រើប្រាស់ក្នុងប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ក្រសួងពាណិជ្ជកម្មបានបញ្ចប់នូវសេចក្តីព្រាងច្បាប់នេះ នឹងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដាក់ប្រជុំជំនាញបច្ចេកទេសជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងក្រុមប្រឹក្សាអ្នកច្បាប់ចាប់តាំងពីខែតុលា ឆ្នាំ២០១៨ រហូតដល់ខែមេសា ឆ្នាំ២០១៩ សរុបប្រជុំ២៤លើរួចមកហើយ៕

## ៣- សិក្ខាសាលាស្តីពី

# ការផ្សព្វផ្សាយសមិទ្ធផលការងារ១០ឆ្នាំ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងការអនុវត្តកម្មវិធីវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត




សិក្ខាសាលានេះបានប្រព្រឹត្តទៅរយៈពេលមួយថ្ងៃពេញ ថ្ងៃពុធ ៦កើត ខែចេត្រ ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ នៅសណ្ឋាគារសុខាភ្នំពេញ ដោយមានការអញ្ជើញចូលរួមពីតំណាងអង្គការជាតិ និងអន្តរជាតិមួយចំនួន រួមទាំងតំណាងក្រសួង ស្ថាប័ន ជុំវិញរាជរដ្ឋាភិបាល សរុបប្រមាណ ២៥៥នាក់។




បន្ទាប់ពីមតិស្វាគមន៍របស់ ឯកឧត្តម **អ៊ុន វ៉ាល់ឡឺរ៉ូ** អគ្គលេខាធិការ ក.ស.វ. លោកស្រី **ជីលូម ទីនីថូម៉ាស**( Jhelum Tinithomas ) មន្ត្រីជំនាញជាន់ខ្ពស់ផ្នែកគ្រប់គ្រងសាធារណៈនៃធនាគារអភិវឌ្ឍន៍អាស៊ីដែលបានអញ្ជើញចូលរួមជាគណៈអធិបតីនាពេលនោះដែរ បានមានប្រសាសន៍ចាប់អារម្មណ៍ដោយវាយតម្លៃខ្ពស់ចំពោះលទ្ធផលការអនុវត្តការងារRIA ក្រោមការគ្រប់គ្រងកម្មវិធីរបស់ ក.ស.វ. និងគូសបញ្ជាក់អំពីសារៈសំខាន់របស់កម្មវិធីRIA ដែលធនាគារអភិវឌ្ឍន៍អាស៊ី បានជួយឧបត្ថម្ភតាំងពីឆ្នាំ២០១០ និងដែលបាននឹងកំពុងដំណើរការប្រកបដោយជោគជ័យ។ លោកស្រី

បានបន្ថែមថា កម្មវិធីRIA អាចដំណើរការដោយមាននិរន្តរភាពលុះត្រាតែមានការបែងចែកថវិកាជាតិដើម្បីគាំទ្រសកម្មភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធខាងវិស័យឯកជនផងដែរ ហើយធនាគារអភិវឌ្ឍន៍អាស៊ីនៅតែជាដៃគូក្នុងការងារRIA ដែលរួមចំណែកក្នុងរបៀបវារៈនៃកំណែទម្រង់។




ក្នុងកម្មវិធីជាបន្ត ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធាន ក.ស.វ. (ECOSOCC) បានធ្វើសុន្ទរកថាបើកអង្គសិក្ខាសាលា។ ឯកឧត្តមបានស្វាគមន៍យ៉ាងកក់ក្តៅចំពោះអ្នកចូលរួមទាំងអស់ ទាំងភ្ញៀវជាតិ និងអន្តរជាតិ។ ឯកឧត្តមមិនបានភ្លេចនឹងគោរពថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់បំផុតជូនចំពោះ សម្តេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុញ្ញាតឲ្យបង្កើត ECOSOCC នេះឡើង ហើយក៏មិនបានភ្លេច នឹងរំលឹកគុណយ៉ាងជ្រាលជ្រៅចំពោះ សម្តេចវិបុលបញ្ញា **សុខ អាន** ដែលមានទំនុកចិត្តលើ ECOSOCC និងបានណែនាំចង្អុលបង្ហាញ ព្រមទាំងគាំទ្រដល់សកម្មភាពការងាររបស់ ECOSOCC។ ព្រមជាមួយគ្នានោះ ឯកឧត្តមបានថ្លែងអំណរគុណជាពិសេសជូនចំពោះ ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយក-រដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានបន្តវាយតម្លៃខ្ពស់ចំពោះតួនាទី និងភារកិច្ចរបស់ ECOSOCC។

បន្ទាប់ពីរំលឹកតួនាទីភារកិច្ចរបស់ ក.ស.វ. និងរំលេចខ្លះៗនូវសមិទ្ធផលជាក់ស្តែងក្នុងរយៈពេល ១០ ឆ្នាំកន្លងមក ឯកឧត្តមប្រធាន បានថ្លែងសរសើរ លើកទឹកចិត្តថ្នាក់ដឹកនាំ សមាជិក សមាជិកា ក.ស.វ. ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានទាំងអស់ ដែលបានខិតខំប្រឹងប្រែងការងាររបស់ខ្លួនយ៉ាងសកម្ម ដោយមានកិច្ចសហការល្អជាមួយអង្គភាពនានាក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។

មុននឹងបញ្ចប់សុន្ទកថាបើក ឯកឧត្តមប្រធានគណៈអធិបតី បានស្នើសុំឲ្យសមាជិក សមាជិកា និងមន្ត្រីអគ្គលេខាធិការដ្ឋានទាំងអស់ ខិតខំបំពេញការងារឲ្យបានសកម្មថែមទៀត និងបានថ្លែងអំណរគុណទុកជាមុនចំពោះវាគ្មិនទាំងឡាយដែលនឹងធ្វើបទបង្ហាញចែករំលែកព័ត៌មាន ផ្លាស់ប្តូរបទពិសោធន៍ក្នុងអង្គសិក្ខា-សាលា ព្រមទាំងស្នើសុំឲ្យសិក្ខាកាមចូលរួមមតិឲ្យបានផុលផុស។ បន្ទាប់ពីជូនពរអ្នកចូលរួមទាំងអស់ ឯកឧត្តមប្រធានបានប្រកាសបើកអង្គសិក្ខាសាលា។

នៅក្នុងសិក្ខាសាលានេះ មានការអញ្ជើញចូលរួមធ្វើបទបង្ហាញលើប្រធានបទផ្សេងៗគ្នា ពីវាគ្មិនចំនួនប្រាំមួយរូប។

ក្នុងបទបង្ហាញលើប្រធានបទទី១ ស្តីពីសមិទ្ធផលការងារ១០ឆ្នាំរបស់ ក.ស.វ. ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានប្រចាំការ ក.ស.វ. និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត (កម្មវិធីRIA) បានលើកឡើងអំពីសមិទ្ធផលការងារនេះជា ៦ចំណុចៈ



ចំណុចទី១-ការងារវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលជាភារកិច្ចចម្បងរបស់ ក.ស.វ. ធ្វើឡើងរៀងរាល់ខែ ត្រីមាស ឆមាសនិងប្រចាំឆ្នាំ ដោយមានការអញ្ជើញចូលរួមយ៉ាងទូលាយពីតំណាងគ្រប់ក្រសួង ស្ថាប័នជុំវិញរាជរដ្ឋាភិបាល។ លទ្ធផលនៃកិច្ចប្រជុំវិភាគស្ថានភាព សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នីមួយៗ ត្រូវបានពិនិត្យ ប្រមូល ចងក្រង បោះពុម្ពជាព្រឹត្តិបត្រ ចែកជូនថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន សរុបក្នុងរយៈពេល ១០ឆ្នាំកន្លងមកនេះ មានប្រមាណជាង ១ម៉ឺនច្បាប់។

ចំណុចទី២-ការងារស្រាវជ្រាវ ដែលក្នុង រយៈពេលកន្លងមកនេះ ផ្តោតទៅលើប្រធានបទចំនួន៩ រួមមាន ១.អង្ករជាប្រភពនៃកំណើតសេដ្ឋកិច្ច ២.ការសិក្សាគម្រោងអភិវឌ្ឍល័ខខ្មែរ ៣.សារៈសំខាន់នៃដំណាំរួមផ្សំក្នុងវិស័យកសិកម្ម ៤.កៅស៊ូក្នុងនាមទំនិញសេដ្ឋកិច្ច ៥.បសុព្យាបាលនិងផលិតកម្មសត្វនៅកម្ពុជា ៦.វិស័យជលផលនិងបញ្ហាប្រឈមនៅកម្ពុជា ៧.ស្ថានភាពដៃគូអភិវឌ្ឍនៅកម្ពុជា ៨.ព្រៃកោងកាងនៅកម្ពុជា និង ៩.លទ្ធផលនៃការសិក្សាវិភាគលើឥណទានមីក្រូហិរញ្ញវត្ថុ។

ចំណុចទី៣-ការងារផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព របាយការណ៍ កិច្ចព្រមព្រៀង និងឯកសារផ្សេងៗ សម្រាប់ដាក់ឆ្លងកិច្ចប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលគិតជាមធ្យមបានចំនួន៣៥៣ ក្នុង១ឆ្នាំ។

ចំណុចទី៤-ការងារអនុវត្តកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដែលជាមុខងារ និងភារកិច្ចបន្ថែមរបស់ ក.ស.វ. ចាប់ពីឆ្នាំ២០១១មក និងដែលមានការពង្រីកបន្ថែមដោយសេចក្តីសម្រេច លេខ ១៣២ សសរ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមការងារRIA ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦។ ក្នុងការងារនេះ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៨ មានការចូលរួមជាបន្តបន្ទាប់ពីក្រសួង ស្ថាប័នចំនួន១៨។

ចំណុចទី៥-ការងារផ្សេងៗដែលថ្នាក់ដឹកនាំនិងសមាជិក បានចូលរួមជាអាទិ៍ គណៈកម្មការអភិរក្ស និងអភិវឌ្ឍតំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ ក្រុមការងារសិក្សាប្លង់គោលអភិវឌ្ឍក្រុងព្រះសីហនុ...។

ចំណុចទី៦-ការងារពិសេសពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលរាជរដ្ឋាភិបាលបានប្រគល់ជូន ឯកឧត្តមប្រធាន ក.ស.វ. ក្នុងឋានៈជាទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេសឲ្យដឹកនាំគម្រោងការងារពិសេសមួយចំនួនមានជាអាទិ៍ គម្រោងសាងសង់អគារមិត្តភាព អគារខាងត្បូងនៃអគារមិត្តភាព និងអគារអង្គរក្សនៃទីស្តីការគណៈរដ្ឋមន្ត្រី។

នៅក្នុងបទបង្ហាញលើប្រធានបទទី២ ស្តីពីសមិទ្ធផលនៃការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចកម្ពុជា(២០០៩-២០១៩) បន្ទាប់ពីបានគូសបញ្ជាក់ថាភារកិច្ចរបស់ ក.ស.វ. និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិមិនមានអ្វីជាន់គ្នាឡើយចមក ឯកឧត្តម **ឈាវ វណ្ណារិទ្ធ** ប្រធានផ្នែកសិក្សានិងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃឧត្តម-ក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ បានលើកឡើងថាប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេល១ទសវត្ស

ចុងក្រោយនេះ ដោយមានការជំរុញខ្លាំងពីវិស័យឧស្សាហកម្ម និងវិស័យទេសចរណ៍ គាំទ្រដោយការកើនឡើងខ្លាំងនៃវិនិយោគផ្ទាល់ពីបរទេសដែលជាបច្ច័យនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពនយោបាយ ប្រែក្លាយកម្ពុជាទៅជាប្រទេសចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥ និងត្រូវបានចាត់ជាខ្លាសេដ្ឋកិច្ចប្រចាំអាស៊ីក្នុងឆ្នាំ២០១៦។ កំណើនសេដ្ឋកិច្ចរឹងមាំ បូកផ្សំនិងការកែទម្រង់រដ្ឋបាលប្រមូលចំណូល បានធ្វើឲ្យចំណូលក្នុងស្រុកសរុបបានកើនឡើងជិត៥ដង នៅចន្លោះឆ្នាំ២០០៩ និង២០១៩ ផ្តល់កាលានុវត្តភាពដល់រាជរដ្ឋាភិបាលក្នុងការបង្កើនចំណាយលើវិស័យអាទិភាពសំខាន់ៗ ជាអាទិ៍ វិស័យសង្គមកិច្ច និងអាចគ្រប់គ្រងឱនភាពថវិកាក្នុងកម្រិតមួយទាប ដែលធ្វើឲ្យស្ថានភាពចំណុលសាធារណៈកម្ពុជា ស្ថិតក្នុងកម្រិតហានិភ័យទាប និងប្រាក់សន្សំរបស់រាជរដ្ឋាភិបាលកើនឡើងជាលំដាប់។

ប្រធានបទទី៣ សម្រាប់ពេលព្រឹកត្រូវបានបង្ហាញជូនដោយលោកស្រីបណ្ឌិត **ច្រាំ ទេវី** អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គមរាជបណ្ឌិត្យសភាកម្ពុជា។ លោកស្រីបានបង្ហាញអំពីការកើតឡើងនៃរាជបណ្ឌិត្យសភាកម្ពុជា ចក្ខុវិស័យ គោលដៅ យុទ្ធសាស្ត្រ រចនាសម្ព័ន្ធ ដៃគូអភិវឌ្ឍន៍ គម្រោងកំពុងអនុវត្ត និងត្រៀមអនុវត្ត ព្រមទាំងកិច្ចការមួយចំនួនទៀតដែលអាចសហការជាមួយនឹង ក.ស.វ.។

នៅពេលបញ្ចប់បទបង្ហាញទាំងបី មានវេទិកាសំណួរចម្លើយ ដែលមានការចូលរួមយ៉ាងទូលំទូលាយពីសមាជិក សមាជិកានៃអង្គសិក្ខាសាលា។




ប្រធានបទទី៤ នាពេលរសៀលស្តីពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (វិធីសាស្ត្រRIA នៅកម្ពុជា) បង្ហាញជូនដោយ ឯកឧត្តម **ម៉ិច សុខា** សមាជិក និងជាអគ្គលេខាធិការរង ក.ស.វ.។ ឯកឧត្តម បានលើកឡើងអំពីទីតាំងនៃកិច្ចការRIA នៅក្នុងដំណើរការរៀបចំនិងការអនុម័តលិខិតបទដ្ឋានគតិយុត្តនៅកម្ពុជានាពេលបច្ចុប្បន្ន អំពីអ្វីទៅជាការវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត អំពីកត្តាជំរុញឲ្យមានRIAនៅកម្ពុជា អំពីវិធីសាស្ត្រRIAនៅកម្ពុជា ដែលមានធាតុផ្សំចំនួន៧ គឺ ១.បញ្ហា ២.គោលបំណង ៣.ជម្រើស ៤.ការវិភាគផលប៉ះពាល់ ៥.កិច្ចពិគ្រោះយោបល់ ៦.សន្និដ្ឋាននិងអនុសាសន៍ និង៧.ការអនុវត្តនិងការត្រួតពិនិត្យ អំពីដំណើរការរៀបចំរបាយការណ៍RIA អំពីលទ្ធផលនៃការវាយតម្លៃបឋមស្តីពីការអនុវត្តRIA ឲ្យមានប្រសិទ្ធភាព និងចំណុចចុងក្រោយគឺសំណូមពរ ដែលស្នើសុំជាពិសេសឲ្យ ADB និងដៃគូអភិវឌ្ឍន៍ដទៃទៀតបន្តគាំទ្រ និងឧបត្ថម្ភកម្មវិធីRIA និងស្នើសុំបង្កើនកម្រិតបញ្ញត្តិកម្មអំពីRIA ឲ្យទៅជាអនុក្រឹត្យឬព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមការងារRIA ដើម្បីលើកកម្ពស់ការអនុវត្តRIA ឲ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលកាន់តែខ្ពស់ និងប្រកបដោយនិរន្តរភាព។

បទបង្ហាញជាបន្តបន្ទាប់ គឺជាការលើកឡើងអំពីការអនុវត្តនិងបទពិសោធន៍ផ្ទាល់នៅតាមក្រសួងឈានមុខចំនួនពីរ គឺក្រសួងអប់រំ យុវជន និងកីឡា បង្ហាញជូនដោយ ឯកឧត្តម **ស៊ិន សេខហុត** ប្រធាននាយក-

ដ្ឋាននីតិកម្ម និងជាប្រធានក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងក្រសួងយុត្តិ-ធម៌ បង្ហាញជូនដោយ ឯកឧត្តម **ជីន ម៉ាលីន** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាប្រធានអង្គភាពវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដែលសុទ្ធតែបានបង្ហាញអំពីសារៈសំខាន់និងលទ្ធផលជាទីមោទនៈនៃការអនុវត្តកម្មវិធីRIAនៅតាមក្រសួងរៀងៗខ្លួន។ បន្ទាប់ពីបទបង្ហាញទាំងបីចុងក្រោយនេះមកក៏មានកម្មវិធីសំណួរចម្លើយ ដូចពេលព្រឹកដែរ។




អង្គសិក្ខាសាលាត្រូវបានរៀបចំបិទ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់នៃទីស្តីការគណៈរដ្ឋមន្ត្រីជាច្រើនរូបចូលរួម។ ក្រោយពីបានស្តាប់របាយការណ៍អំពីលទ្ធផលអង្គសិក្ខាសាលាដែល ឯកឧត្តម អនុប្រធានប្រចាំការ ក.ស.វ. បានអានជូន ឯកឧត្តម **ឧបនាយករដ្ឋមន្ត្រី** បានមានមតិវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលរយៈពេល១០ឆ្នាំរបស់ក.ស.វ. និងលទ្ធផល នៃការអនុវត្តកម្មវិធីវាយតម្លៃលើផលប៉ះ-ពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដឹកនាំដោយ ក.ស.វ. ដែលមានដែលមានក្រសួង ស្ថាប័នចំនួន១៨ ចូលរួម ព្រមទាំងបានជំរុញឲ្យសមាជិក សមាជិកា និងមន្ត្រីរបស់ ក.ស.វ. បន្តខិតខំបំពេញការងារឲ្យកាន់តែប្រសើរឡើងទៀត។ ឯកឧត្តម **ឧបនាយករដ្ឋមន្ត្រី** ក៏បានស្នើឲ្យធនាគារអភិវឌ្ឍន៍អាស៊ីបន្តគាំទ្រកម្មវិធីRIA ឲ្យបានទូលំទូលាយដល់ក្រសួង ស្ថាប័នដ៏ទៃទៀតផងដែរ។

អង្គសិក្ខាសាលាត្រូវបានបិទបញ្ចប់ដោយជោគជ័យ នៅវេលាម៉ោង ៥:៥០ ក្រោមបរិយាកាសរីករាយ និងស្និទស្នាល៕





# IV- ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំត្រីមាសទី១ឆ្នាំ២០១៩



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា **ប្រចាំត្រីមាសទី១ឆ្នាំ២០១៩** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៩ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង នៃ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងត្រីមាសទី១ ឆ្នាំ២០១៩នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

| ល.រ | សូចនាករ | ធៀបនឹងត្រីមាសមុន | ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ១ | ក្រុមភោជនីយដ្ឋាន | ២,៨% | ៧,១% |
| ២ | ភេសជ្ជៈមានជាតិស្រវឹង និងថ្នាជក់ | ២,២% | ៦,៥% |
| ៣ | ឧស្ម័ន | ០,៥% | ៥,៤% |
| ៤ | សំណង់អនុញ្ញាតឲ្យសាងសង់ (ពាន់ ម²) | ១៤១% | ២២២% |
| ៥ | សំណង់លំនៅឋានអនុញ្ញាតឲ្យសាងសង់ (ពាន់ ម²) | ១៨២% | ៣០៨% |

## ២) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់

➡ នាត្រីមាសទី១ ឆ្នាំ២០១៩ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង ០,១៨% ធៀបនឹងត្រីមាសមុន និងកើនឡើង ១,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង២.១. បម្រែបម្រួលថ្លៃធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៧,១% | ឧស្ម័ន: | +៥,៤% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +៦,៥% | សាច់មាន់ស្រស់: | +៣,៧% |
| សំលៀកបំពាក់ និងស្បែកជើង: | +៣,២% | បន្លែ: | +៣,២% |
| ម្ហូបអាហារ: | +២,១% | សាច់គោស្រស់: | +១,៨% |
| សុខាភិបាល: | +២,១% | ត្រីស្រស់: | +១,៦% |
| ការកម្សាន្ត និងវប្បធម៌: | +១,០% | ផ្លែឈើ: | +១,៥% |
| ទំនិញ និងសេវាកម្មផ្សេងៗ: | +១,០% | | |

* ការវិភាគជាសំណេរដេកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

តារាង២.២. អត្រាប្តូរប្រាក់

| បរិយាយ | ត្រីមាសទី១ ២០១៩ | ត្រីមាសទី៤ ២០១៨ | ត្រីមាសទី១ ២០១៨ | បរិយាយ | ត្រីមាសទី១ ២០១៩ | ត្រីមាសទី៤ ២០១៨ | ត្រីមាសទី១ ២០១៨ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០១៥៛/$ | ៤០១៨៛/$ | ៤០០០៛/$ | **បាត/ដុល្លារ** | ៣១,៨១បាត/$ | ៣២,៥១បាត/$ | ៣១,២៤បាត/$ |
| **៛/បាត** | ១២៦៛/បាត | ១២៤៛/បាត | ១២៨៛/បាត | **ដុង/ដុល្លារ** | ២៣២០០ដុង/$ | ២៣១៥០ដុង/$ | ២២៨០៥ដុង/$ |
| **៛/ដុង** | ០,១៧៣៛/ដុង | ០,១៧៤៛/ដុង | ០,១៧៥៛/ដុង | | | | |

## ៣) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**៣.១. ចំណូលថវិកាជាតិ** : អនុវត្តបាន៤៨៩៨,៩ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១២២៤,៧ លានដុល្លារ ( *មធ្យមប្រចាំខែ ៩៧,៨% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន៤៨៦៨,៣ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ១២១៧,០ លានដុល្លារ ( *មធ្យមប្រចាំខែ ៩៩% នៃផែនការ*) និងចំណូលមូលធនចំនួន៣០,៣ប៊ីលានរៀល( តាមតួលេខ រតនាគារជាតិ )។

ក្រាហ្វ ៣.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៨–២០១៩ (ប៊ីលានរៀល)




➢បើធៀបនឹងត្រីមាសមុន ចំណូលថវិកាជាតិថយចុះ១៣,១% ប៉ុន្តែកើនឡើង១១,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ ២០១៨ និង២០១៩។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ៤៣៧៨,៧ប៊ីលានរៀល ថយចុះ៤,៨% ធៀបនឹងត្រីមាសមុនប៉ុន្តែកើនឡើង ៩,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន( តាមតួលេខ រតនាគារជាតិ )។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន៤៨៩,៥ប៊ីលានរៀលថយចុះ៤៨,៤% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៣៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន( តាមតួលេខ រតនាគារជាតិ )។

**តារាង៣.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: :+១,០%) (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+២៣,៧%) | ➢អាជ្ញាបណ្ណក្នុងស្រុក : -៩០,៩% | (+២១,២%) |
| | | ➢ នេសាទ:+៣០,៨% | (+១៣១,៩%) |
| ➢ ចំណូលពន្ធដារ: -៥,០% (អគ្គនាយកដ្ឋានពន្ធដារ) | (+១១,១%) | ➢សម្បទានរ៉ែ: -៧៦,១% | (-២៧,៥%) |
| | | ➢ផលទុនសកម្មភាពទេសចរណ៍-៦៥,៤% | (-៥៦,១%) |

៣.២. **ចំណាយថវិកាជាតិ** : អនុវត្តបាន ៣២៧៩,២ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៨១៩,៨ លានដុល្លារ (*មធ្យមប្រចាំខែ ៦៤% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ២៨៦៥,៩ប៊ីលានរៀល (*មធ្យមប្រចាំខែ ៦៥% នៃផែនការ*) និងចំណាយមូលធនមានចំនួន៤១៣,៣ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិថយចុះ៣៥,៤% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៤,៩%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ៣២,៣% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៣,៥%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

**៣.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាត្រីមាសទី១ នេះមានអតិរេកចំនួន ១៦១៩,៧ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៤០៤,៩លានដុល្លារ (តួលេខរតនាគារជាតិ)។

ក្រាហ្វ៣.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៨-២០១៩
(ប៊ីលានរៀល)




## ៤) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងត្រីមាសទី១ ឆ្នាំ២០១៩មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន៩៣០១៦ប៊ីលានរៀល កើនឡើង៥,២% ធៀបនឹងត្រីមាសមុន និងកើនឡើង២៣,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ **ការកើនឡើង**$M_2$ ជារួមបណ្តាលមកពីកំណើននៃរូបិយវត្ថុក្រៅធនាគារ ប្រាក់បញ្ញើចរន្ត និងប្រាក់បញ្ញើជារូបិយបណ្ណ ។

ក្រាហ្វ៤.១. សមាសធាតុរូបិយវត្ថុត្រីមាសទី១ ឆ្នាំ២០១៩




ក្រាហ្វ៤.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុត្រីមាសទី១ ២០១៩: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន



➤**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន១០៥៣៥ លានដុល្លារ កើនឡើង៤,៨%ធៀបនឹងត្រីមាសមុន និងកើនឡើង១៩,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➤ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងត្រីមាសនេះមានចំនួន ៣១១៣៤ ប៊ីលានរៀលកើនឡើង១,៩%ធៀបនឹងត្រីមាសមុន និងកើនឡើង១៤,៤%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង៤.៣.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *ត្រីមាសទី១ ២០១៩* | *ត្រីមាសទី៤ ២០១៨* | *ត្រីមាសទី១ ២០១៨* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល) | ៨៧៥៦៤ | ៨៤៧៣៦ | ៧០៣០០ |
| ក្នុងនោះ ជារៀល | — | ៣៥២៦ | ១៨៧១ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | — | ២១៨១៣ | ១៨៤៧៥ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,១១% | ៦,១៧% | ៦,០៤% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៣៦% | ៤,៤២% | ៤,៤២% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៣,៦២% | ១៣,៧០% | ១២,០៣% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៨១% | ១១,៧៨% | ១១,៤៥% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថកសិករ | ១៧,៩% | ១៧,៩% | ១៨,០% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | ១៨% | ១៧,៨% | ១៨,០% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | ១៦,៨% | ១៧,០% | ១៦,១% |

## ៥)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➤**កសិកម្ម**:

✓នេសាទសម្រេចបាន១៦០,៨ពាន់តោន ថយចុះ៥៣,១% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៤,៩%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➤**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន២៦៤៣,០៧GWHមានការកើនឡើង៣,៤% ធៀបនឹងត្រីមាសមុន និងកើនឡើង២៥,២%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ៤៦០,៥GWHមានការ ថយចុះ៥៩,២% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៨,៣%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន១០៩៧,៧១GWHមានការកើនឡើង៣២,៨%ធៀបនឹងត្រីមាសមុន និងមានការ កើនឡើង១,៥%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDC មានចំនួន៧៨៨,៦៤GWHមានការ កើនឡើង៦៥,៨%ធៀបនឹងត្រីមាសមុន និងមានការកើនឡើង៦៦,២%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន២៩៦,២៥GWHមានការកើនឡើង១៣៤,៦% ធៀបនឹងត្រីមាសមុន និងមានការកើនឡើង១២៦,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➤**ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ១៨២៩,៤លានដុល្លា មានការថយចុះ១១,៦% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង១,៦%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។

តារាង៥.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –ត្រីមាសទី១ ២០១៩ | ចំនួន–ត្រីមាសទី៤ ២០១៨ | ចំនួន–ត្រីមាសទី១ ២០១៨ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៥៩ | ៤៩ | ៣៤ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៥៧១ | ១៥២៨ | ១៥៥៦ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១១ | ១១ | ៤៧ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១០ | ១៨ | ១០១ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន៣៨២០,៩ពាន់ម៉ែ២ មានការកើនឡើង១៤១,០% ធៀបនឹងត្រីមាសមុន និងកើនឡើង២២២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង១៧០២លានដុល្លារ មានការកើនឡើង៨២,០% ធៀបនឹងត្រីមាសមុន និងកើនឡើង២៣៦,០% បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៥.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម៉ែ២ – ត្រីមាសទី១ ២០១៩ | ពាន់ម៉ែ២ –ត្រីមាសទី៤២០១៨ | ពាន់ម៉ែ២ –ត្រីមាសទី១ ២០១៨ |
|---|---|---|---|
| ▪ លំនៅឋាន | ២៥៥៩,៨ | ៩០៦,៩ | ៦២៧,៣ |
| ▪ ឧស្សាហកម្ម | ៣០៩,៨ | ១១៤,៣ | ១៩៤,៣ |
| ▪ពាណិជ្ជកម្ម | ៧៨៩,០ | ៤៨១,១ | ២៩៩.០ |
| ▪ ទេសចរណ៍ | ១១០,៧ | ៨០,១ | ៥៦,៩ |
| ▪ផ្សេងៗ | ១,៩ | ២,៧ | ៥,៦ |
| អនុញ្ញាតសរុប | ៣៨២០,៩ | ១៥៨៦,៦ | ១១៨៧,៩ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាត្រីមាសនេះគឺ លំនៅដ្ឋាន ៦៧,០% និងពាណិជ្ជកម្ម២០,៦% នៃផ្ទៃក្រឡាសរុប។

➢**ការងារ**

តារាង៥.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់– ត្រីមាសទី១ ២០១៩ | នាក់–ត្រីមាសទី៤ ២០១៨ | នាក់–ត្រីមាសទី១ ២០១៨ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ(ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ៤៤៧៦ | ៤៤៧៦ | ៤៣៥៦ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៥២៩៨០ | ៥៧០៣១ | ៤៥៦៣៥ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៣៨៥០២ | ៣៩៧៣៧ | ៣១៧០០ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៤៤៧៨ | ១៧២៩៤ | ១៣៩៣៥ |

➢**វិនិយោគ**

តារាង៥.៤.គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | ត្រីមាសទី១ ២០១៩ | ត្រីមាសទី៤ ២០១៨ | ត្រីមាសទី១ ២០១៨ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ២៣២៤,៥ | ២០៣១,៧ | ៦៨៤,៨ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០,០ | ៨៥,២ | ២១៥,៣ |
| វិស័យឧស្សាហកម្ម (ក្នុងរង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៦៩៨,៩ (៣៦៣,៤) | ២៧៦,៧ (១៣២,១) | ៣៦១,២ (១៥៦,២) |

| | | | |
|---|---|---|---|
| វិស័យទេសចរណ៍ | ១៦១៨,៨ | ១២៤៨,៦ | ៧៥,២ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៦,៨ | ៥៨,២ | ៣៣,១ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៩៤ | ៨៦ | ៦៤ |
| បង្កើតការងារ (ពាន់នាក់) | ១១២,៧ | ៤៣,៩ | ៤៧,៥ |

➤ **សេវាកម្ម**

តារាង៥.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| *ប្រភេទ* | *ចំនួន—ត្រីមាសទី១ ២០១៩* | *ចំនួន—ត្រីមាសទី៤ ២០១៨* | *ចំនួន—ត្រីមាសទី១ ២០១៨* |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៤២០៨ | ៣០៧០ | ២៧៧៣ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៣៣ | ៣១ | ២៨ |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ២៥៩១ | ៣៦៤០ | ១៨៧៩ |

➤**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ) មានចំនួន២៤៤៧,២ពាន់តោន មានការថយចុះ៨,០% ធៀបនឹងត្រីមាសមុននិងមានការថយចុះ៧,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ក្នុងនោះៈ

តារាង៥.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)

| | |
|---|---|
| ▪ កំពង់ផែភ្នំពេញ:+៧,៤% (+២៧,០%) | ▪ កំពង់ផែកំពង់សោម:-១៥,២% (-១៨,៥%) |

➤**ប្រៃសណីយ៍និងទូរគមនាគមន៍**

| *ប្រភេទ* | *ចំនួន* | *%Δ ធៀបនឹងត្រីមាសមុន* | *%Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន* |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ៦០,៤ | ៣,៩% | ២,១% |
| ក្នុងនោះទទួល | ៧,២ | ១៤,៩% | -១,៨% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៣០៧,៤ | -១,៦% | -១៤,១% |
| ក្នុងនោះទទួល | ១៦០,២ | -៧,៧% | -៥,០% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ៤៩០០,៤ | -៦,៥% | -១៩,៣% |
| ក្នុងនោះហៅចូល | ១៥១៣,០ | -៣,៧% | -១៥,៦% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ២០៧៧៦,០ | ១០,៩% | ៦,១% |
| ក្នុងនោះហៅចូល | ២០៥៧៧,៧ | ១១,០% | ៦,៥% |

➤ **ការធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍**

តារាង៥.៧.អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| *ប្រភេទ* | *ចំនួន(ពាន់នាក់)* | *%Δ ធៀបនឹងត្រីមាសមុន* | *%Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន* |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៦៧,៦ | ១៣,៩% | -១១,១% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២០៧,៤ | ២០,៤% | ០,៤% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ២៨៨៨,០ | ១១,៣% | ១១,៣% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៤៥៦,៩ | -១៤,៨% | ៣,៩% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ១៨៧៧,៩ | ២,៩% | ៩,៧% |
| ✓ តាមផ្លូវអាកាស | ១២៩៩,១ | ១៤,២% | ១២,២% |
| ✓ តាមផ្លូវគោក និងទឹក | ៥៧៨,៧ | -១៥,៨% | -៤,៥% |

## ៦) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាត្រីមាសទី១ ឆ្នាំ២០១៩ មានចំនួន១៧៦៦៨,៥ ប៊ីលានរៀល (ស្មើនឹង៤៤១៧,១លានដុល្លារ ស.រ.អា.) ថយចុះ១១,១% ធៀបនឹងត្រីមាសមុនប៉ុន្តែកើនឡើង២២,៥%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៦.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %∆ធៀបនឹង ត្រីមាសមុន | %∆ធៀបនឹងត្រីមាស ដូចគ្នាឆ្នាំមុន | ទំនិញ | %∆□ធៀបនឹង ត្រីមាសមុន | %∆ធៀបនឹងត្រីមាស ដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +១២,២% | +១៧,៦% | រថយន្តសរុប (ប៊ី.ល.រ) | -០,២% | +៥៦,៤% |
| ប្រេងម៉ាស៊ូត | +៧,៣% | +៣២,៤% | រថយន្តសរុប (គ្រឿង) | -៩,៥% | +២៣,៨% |
| ឧស្ម័ន | -២,៣% | +៣៣,១% | ត្រាក់ទ័រនិងគោយន្ត | -២៣,២% | -២១,៥% |
| អគ្គិសនីនាំចូលដោយ | +៦៥,៨% | +៦៦,២% | ម៉ូតូ (គ្រឿង) | -២៥,៣% | -២៧,០% |
| ដែកសំណង់ | +៥១,៩% | +៥៧,១% | អង្ករ | +២០៩,៥% | +៣២៤,៣% |
| ស៊ីម៉ង់ត៍ | +២២,៧% | -២៤,២% | ផ្លែឈើនិងបន្លែ | -១០,៦% | -៧,៣% |
| គ្រឿងអេឡិចត្រូនិក | -៥៨,៥% | +៦២២,៥% | ថ្នាំកសិកម្ម | -៩៩,៥% | -៩៤,៣% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់ | -១០,២% | +២,៥% |

➡ **ការនាំចេញ** ត្រីមាសទី១ ឆ្នាំ២០១៩ មានចំនួន**១២៩១៦,៤**ប៊ីលានរៀល ស្មើនឹង**៣២២៩,១**លានដុល្លារ ស.រ.អា. (**៧៣,១%** នៃការនាំចូល)កើនឡើង២,០% ធៀបនឹងត្រីមាសមុន និងកើនឡើង១២,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង៦.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| *ទំនិញ* | *%∆ធៀបនឹង ត្រីមាសមុន* | *%∆ធៀបនឹងត្រីមាស ដូចគ្នាឆ្នាំមុន* | *ទំនិញ* | *%∆ធៀបនឹង ត្រីមាសមុន* | *%∆ធៀបនឹងត្រីមាស ដូចគ្នាឆ្នាំមុន* |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +១២១,២% | -៤៦,៣% | ផលិតផលនេសាទ | -៤០,៤% | -២៤,៥% |
| វាយនភណ្ឌនិងស្បែកជើង | +៦,៥% | +១៦,៤% | កៅស៊ូ | -៤០,០% | -៤,៨% |
| អង្ករ | -១៣,៤% | +១,១% | | | |



# សកម្មភាពការងារក្នុងត្រីមាសទី២ ឆ្នាំ២០១៩ កម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (កម្មវិធីRIA) ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទីស្តីការគណៈរដ្ឋមន្ត្រី

នៅក្នុងត្រីមាសទី២ ឆ្នាំ២០១៩ ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត (RET) នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) បានសម្របសម្រួល សហការជាមួយក្រសួងស្ថាប័នចំនួន១៨ ទទួលបានលទ្ធផលគួរឲ្យកត់សម្គាល់មួយចំនួនដូចជាការកសាងសមត្ថភាព ការងារផ្សព្វផ្សាយកម្មវិធី RIAដល់អគ្គនាយដ្ឋាន និងនាយកដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី មន្ត្រីរាជការក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងការផ្សព្វផ្សាយពីសមិទ្ធផល១០ឆ្នាំរបស់ ក.ស.វ. និងកម្មវិធីRIA ចំនួន៦លើក ដែលមានសិក្ខាកាមចូលរួមសរុបចំនួន១០៧០រូប។ លទ្ធផលសម្រេចបានក្នុងត្រីមាសទី២ ឆ្នាំ២០១៩ ចែកចេញជាបីផ្នែកធំៗ (ក)ការកសាងសមត្ថភាព (ខ)ការផ្សព្វផ្សាយនិងពិគ្រោះយោបល់ (គ)កិច្ចប្រជុំដើម្បីត្រួតពិនិត្យនិងគ្រប់គ្រងកម្មវិធី ដែលលម្អិតដូចខាងក្រោម៖

## ក- ការកសាងសមត្ថភាព

ចាប់ពីថ្ងៃទី ២៨ ដល់ ៣១ ខែ ឧសភា ឆ្នាំ២០១៩ ក្រុមRET បានផ្តល់វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្រ្ត RIA ដល់មន្ត្រីក្រុមការងារ RIA មកពី ១៥



ក្រសួង ស្ថាប័ន ដែលមានអ្នកចូលរួមសរុបចំនួន ៩០ រូប។

## ខ- ការងារផ្សព្វផ្សាយកម្មវិធីRIA និងពិគ្រោះយោបល់

១- នៅព្រឹកថ្ងៃពុធ ១កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ ក្រុមRET សហការជាមួយក្រុមការងារRIA




ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធី និងវិធីសាស្រ្តវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ជូនដល់និស្សិតច្បាប់ នៅសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបាត់ដំបង មានសិក្ខាកាមចូលរួមសរុប ២០០រូប។

២- នៅថ្ងៃព្រហស្បតិ៍ ២កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩ ក្រុមRET សហការជាមួយក្រុមការងារRIA ក្រសួងអប់រំ យុវជន និងកីឡា បានការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធី និងវិធីសាស្រ្តវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ជូន



ដល់និស្សិតច្បាប់ នៅសាកលវិទ្យាល័យបៀលប្រាយ ខេត្តសៀមរាប មានសិក្ខាកាមចូលរួមសរុប ១៥០ រូប។

៣. ថ្ងៃអង្គារ ៧ កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ ក្រុមRET សហការជាមួយក្រុមការងារRIA



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីRIA និងលទ្ធផលស្តីពីការវាយតម្លៃបឋមលើសេចក្តីព្រាងប្រកាសស្តីពីវិធានសម្រាប់គ្រប់គ្រងនិងដំណើរការសហគ្រាស សិប្បកម្មផលិតទឹកពិសារដប ដល់មន្ត្រីរាជការ សិប្បករ និងផ្នែកឯកជន ចំនួន ២១០នាក់។

៤. នៅថ្ងៃសុក្រ ១០កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ក្រុមRET សហការជាមួយក្រុមការងារRIA ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធី និងវិធីសាស្រ្តវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ជូនដល់និស្សិតច្បាប់ នៅសាលកវិទ្យាល័យជាស៊ីមកំចាយមារ



ខេត្តកំពង់ចាម មានសិក្ខាកាមចូលរួម សរុបចំនួន ១៥០រូប។

៥. នៅថ្ងៃអង្គារ ១៤ កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ក្រុមRET បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីនិងវិធីសាស្រ្តវាយតម្លៃលើផលប៉ះពាល់



នៃលិខិតបទដ្ឋានគតិយុត្ត(វិធីសាស្រ្តRIA) ដែលមានការចូលរួមពីអគ្គនាយដ្ឋានចំនួន៨ និងនាយកដ្ឋានចំនួន២៦ចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានអ្នកចូលរួមសរុបចំនួន ៦០រូប។

៦. នៅថ្ងៃពុធ ៦កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឧបត្ថម្ភថវិការដោយធនាគារអភិវឌ្ឍន៍អាស៊ី បានរៀបចំសិក្ខាសាលាការផ្សព្វផ្សាយស្តីពីសមិទ្ធផលការងារ១០ឆ្នាំរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងការអនុវត្តកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត។

## គ- ការពិគ្រោះយោបល់ ស្ទង់មតិ និងប្រមូលទិន្នន័យ

ចាប់ពីថ្ងៃទី២ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ ក្រុមRET បានសហការជាមួយក្រុមការងារRIA របស់ក្រសួងឧស្សាហកម្មនិងសិប្បកម្មចុះពិគ្រោះយោបល់ និងស្ទង់មតិជាមួយភាគីពាក់ព័ន្ធ ដើម្បីប្រមូលទិន្នន័យ សម្រាប់រៀបចំរបាយការណ៍វាយតម្លៃបឋមលើផល-



ប៉ះពាល់សេចក្តីកែសម្រួលប្រកាសស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ នៅខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង ប៉ៃលិន កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង ព្រះសីហនុ កោះកុង និងកំពត ដែលមានអ្នកចូលរួមសរុបចំនួន ៣២៧រូប។

ចាប់ពីថ្ងៃទី ១៦ដល់២៧ ខែមីនា និងចាប់ពីថ្ងៃទី២៨ ខែមេសា ដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០១៩ ក្រុមRET បានសហការជាមួយក្រុមការងារ RIA ក្រសួងអប់រំ យុវជននិងកីឡា ចុះពិគ្រោះយោបល់ និងស្ទង់មតិជាមួយភាគីពាក់ព័ន្ធ ដើម្បីប្រមូលទិន្នន័យសម្រាប់រៀបចំរបាយការណ៍វាយតម្លៃបឋមលើផលប៉ះពាល់ នៃសេចក្តីព្រាងប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀងក្នុងវិស័យអប់រំ នៅខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តមមានជ័យ សៀមរាប កំពង់ចាម ក្រចេះ ស្ទឹងត្រែង រតនគីរី មណ្ឌលគីរី តាកែវ កំពត កែប ព្រះសីហនុ និងកំពង់ស្ពឺ។



ថ្ងៃទី១៩ ដល់២២ ខែ ឧសភា ឆ្នាំ ២០១៩ ក្រុមRET បានជួបប្រជុំជាមួយក្រុមការងារRIA ក្រសួងអប់រំ យុវជននិងកីឡា ដើម្បីបូកសរុបលទ្ធផលការងារ និងពិនិត្យលើផែនការយុទ្ធសាស្រ្ត ដែលមានអ្នកចូលរួមសុបចំនួន ១៧រូប។

## ឃ- ការងារត្រួតពិនិត្យ និងគ្រប់គ្រងកម្មវិធីRIA

ក្នុងត្រីមាសទី២ ឆ្នាំ២០១៩ ក្រុមRET និង ADB បានជ្រើសរើសទីប្រឹក្សាកម្មវិធីRIA Mrs. Eleanor Mak ដើម្បីសិក្សាវាយតម្លៃការអនុវត្តកម្មវិធីRIA នៅកម្ពុជា ដែលទទួលបានលទ្ធផលដូចខាងក្រោម៖



១-បានកែសម្រួលទម្រង់និងនិតិវិធីនៃការរៀបចំរបាយការណ៍RIA ដើម្បីឲ្យមានភាពងាយស្រួល ហើយត្រូវនឹងបរិបទកម្ពុជា។

២-បានចេញរបាយការណ៍វាយតម្លៃកម្មវិធី RIA និងអនុសាសន៍សម្រាប់អនុវត្តបន្តឲ្យមាននិរន្តរភាព។

ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០១៩ ក្រុមការងារRIA បានរៀបចំដំណើរទស្សនៈ



កិច្ចសិក្សា ( Retreat ) នៅខេត្តស្ទឹងត្រែង ដែលដឹកនាំដោយឯកឧត្តម **ឃឹម ណុលសន** អនុប្រធានប្រចាំការក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ( RET ) ហើយមានសិក្ខាកាមសរុបចំនួន ៩០នាក់ មកពីក្រសួង ស្ថាប័ន ដែលអនុវត្តកម្មវិធីRIA ចំនួន ១៩ ចូលរួម។

ក្នុងដំណើរសិក្សានេះមានកម្មវិធីដូចខាងក្រោម៖

-បទបង្ហាញអំពីស្ថានភាពនៃការអនុវត្តRIA កន្លងមក

-បទបង្ហាញអំពីការសិក្សាវាយតម្លៃលើការអនុវត្តកម្មវិធីRIAនៅកម្ពុជា

-ការចែករំលែកបទពិសោធន៍នៃការអនុវត្តRIAនៅក្រសួងអប់រំ យុវជន និងកីឡា ដែលជាក្រសួងឈានមុខគេក្នុងកម្មវិធីRIA

-បទបង្ហាញអំពីការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យច្បាប់និងលិខិតបទដ្ឋានគតិយុត្តកម្ពុជា

-អគ្គិសនីកម្ពុជាបានរៀបចំឲ្យសិក្ខាកាមចុះទស្សនាទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលសាងសង់ និងដំណើរការដោយក្រុមហ៊ុនចិន។







ក្រុមហ៊ុនចិនក៏បានធ្វើបទបង្ហាញអំពីគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ ព្រមទាំងផលប៉ះ-ពាល់ និងដំណោះស្រាយផ្សេងៗផងដែរ។ បន្ទាប់មកក្រុមការងារបានចុះទៅពិនិត្យផ្ទាល់នៅទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលមានទួរប៊ីនចំនួន ៨ កំលាំងសរុប ៤០០មេហ្គាវ៉ាត់។

នៅថ្ងៃទស្សនៈកិច្ចនេះ យើងឃើញដំណើការបានតែ ៥ទួរប៊ីនប៉ុណ្ណោះ ដោយសាររដូវប្រាំង។










ចាប់ពីដើមឆ្នាំ២០១៩នេះ ក្រុមការងារផ្នែកប្រព័ន្ធគ្រប់គ្រងឯកសារ ទិន្នន័យ និងព័ត៌មាន នៃអគ្គលេខាធិការដ្ឋាន ក.ស.វ. បានបង្កើតប្រព័ន្ធគ្រប់គ្រងលិខិតបទដ្ឋានគតិយុត្ត ជាប្រព័ន្ធមួយដែលអាចអនុញ្ញាតឲ្យយើងស្វែងរកនូវលិខិតបទដ្ឋានគតិយុត្តនានារបស់កម្ពុជា តាមរយៈឈ្មោះ ប្រភេទ ឆ្នាំ និងក្រសួងស្ថាប័ន។ ដោយ បែងចេញជាពីរផ្នែកៈ

១-បង្កើតប្រព័ន្ធគ្រប់គ្រងលិខិតបទដ្ឋានគតិយុត្តដោយតំឡើងទៅក្នុងម៉ាស៊ីនមេ( Server ) ដែលអាចអោយយើងប្រើប្រាស់ជាលក្ខណៈផ្ទៃក្នុង។



២-បង្ហោះលិខិតបទដ្ឋានគតិយុត្តដែលមានក្នុងប្រព័ន្ធផ្ទៃក្នុងទៅក្នុងគេហទំព័ររបស់ ក.ស.វ www.ecosocc.gov.kh ដើម្បីអោយសាធារណៈជនអាចចូលស្វែងរកបាន៕



## សកម្មភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែមីនា ឆ្នាំ២០១៩ |
|---|---|---|
| ១ | ០៤/០៣/១៩ **ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានសាងសង់គម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយ-លូ ក្នុងរាជធានីភ្នំពេញ ដំណាក់កាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសួនច្បារមុខវត្តបុទុមវតី រាជធានីភ្នំពេញ។ |
| ២ | ០៥/០៣/១៩ **ម៉ោង០៨:៣០នាទី** | ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីអបអរសាទរខួបលើកទី១០៨ ទិវាអន្តរជាតិនារី ៨ មីនា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៣ | ០៦/០៣/១៩ **ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៦/០៣/១៩ **ម៉ោង១៥:៤០នាទី** | ចូលរួមជាគណៈអធិបតី ក្នុងពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេស អបអរសាទរទិវាវប្បធម៌ជាតិ៣មីនា លើកទី២១ ឆ្នាំ២០១៩ និងពិធីសំណេះសំណាលពិសារអាហារសាមគ្គី រវាងប្រមុខរាជរដ្ឋាភិបាល និងសិល្បករ សិល្បការិនី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៥ | ០៧/០៣/១៩ **ម៉ោង០៧:៣០នាទី** | ចូលរួមជាគណៈអធិបតី ក្នុងពិធីអបអរសាទរខួបលើកទី១០៨ ទិវាអន្តរជាតិនារី ៨ មីនា ក្រោមប្រធានបទ "លើកកម្ពស់សមភាពយេនឌ័រ និងគាំពារសង្គមដើម្បីអភិវឌ្ឍធនធានមនុស្ស" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការ គណៈរដ្ឋមន្ត្រី។ |
| ៦ | ០៨/០៣/១៩ **ម៉ោង១០:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយមូលនិធិត្រីចក្រយាន និងពិសារបាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៧ | ០៨/០៣/១៩ **ម៉ោង១៦:០០នាទី** | ចូលរួមប្រជុំពិភាក្សាអំពីលទ្ធភាពដោះស្រាយជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ស្រុក ក្រុង ខណ្ឌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ១១/០៣/១៩ **ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |

| | | |
|---|---|---|
| ៩ | **១២/០៣/១៩ ម៉ោង០៩:០០នាទី** | ចូលរួមជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ នៅសាលប្រជុំសាលាខេត្តតាកែវ។ |
| ១០ | **១៤/០៣/១៩ ម៉ោង០៧:៤៥នាទី** | ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៨-២០១៩ និងទិសដៅការងារឆ្នាំ២០១៩-២០២០ ក្រោមអធិ-បតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ |
| ១១ | **១៥/០៣/១៩ ម៉ោង១២:៣០នាទី** | ចូលរួមក្នុងវេទិកាធុរកិច្ចអមដោយពិធីជប់លៀងជូន ឯកឧត្តម **មូន ចេអ៊ីន** ប្រធានា-ធិបតីនៃសាធារណ-រដ្ឋកូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១២ | **១៨/០៣/១៩ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់វិញ្ញាបនបត្រ សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់សិក្ខាកាមនិស្សិតវិទ្យាស្ថានខ្មែរជំនាន់ថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១៣ | **១៩/០៣/១៩ ម៉ោង០៨:០០នាទី** | ចូលរួមអបអរសាទរ ក្នុងពិធីប្រគល់សញ្ញាបត្របណ្ឌិតកិត្តិយស ផ្នែកទំនាក់ទំនងនយោបាយ ពីសាកលវិទ្យាល័យគ្រើក(Krirk) ជូន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៤ | **២១/០៣/១៩ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជូនដល់និស្សិតសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១៥ | **២២/០៣/១៩ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំលទ្ធផលបូកសរុបការងាររយៈពេល១០ឆ្នាំ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | **២៥/០៣/១៩ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៧-២០១៨ និងលើកទិសដៅឆ្នាំសិក្សា២០១៨-២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |

| | | |
|---|---|---|
| ១៧ | **២៦/០៣/១៩ ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍សង្ខេបស្តីពីសមិទ្ធផលការងាររយៈពេល១០ឆ្នាំ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | **២៧/០៣/១៩ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រជូននិស្សិតអធិការអប់រំជំនាន់ទី៣ និស្សិតឯកទេសវិជ្ជាជីវៈ នាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី១ គ្រូបង្រៀនកម្រិតមូលដ្ឋានតាមប្រព័ន្ធពន្លឿនឆ្ពោះទៅកម្រិតបរិញ្ញាបត្រជំនាន់២ និងគ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសបារាំង-ខ្មែរជំនាន់ទី១៩ នៃវិទ្យាស្ថានជាតិអប់រំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១៩ | **២៧/០៣/១៩ ម៉ោង១៥:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំ២០១៧-២០១៨ និងលើកទិសដៅឆ្នាំសិក្សា២០១៨-២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |
| ២០ | **២៨/០៣/១៩ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរគម្រប់ខួប១០០ឆ្នាំ នៃការបង្កើតអង្គការអន្តរជាតិខាងការងារ និងខួប៥០ឆ្នាំ នៃសមាជិកភាពកម្ពុជានៅអង្គការអន្តរជាតិខាងការងារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២១ | **២៩/០៣/១៩ ម៉ោង០៨:០០នាទី** | ចូលរួមក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| **ល.រ** | **កាលបរិច្ឆេទ** | **សកម្មភាពក្នុងខែមេសា ឆ្នាំ២០១៩** |
| ១ | **០១/០៤/១៩ ម៉ោង០៧:១៥នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតវិទ្យាស្ថានវ៉ាន់ដា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ។ |
| ២ | **០២/០៤/១៩ ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីពិភាក្សាពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| | | |
|---|---|---|
| ៣ | ០៣/០៤/១៩<br>**ម៉ោង១៥:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត។<br>២- សំណើសុំការពិនិត្យសម្រេចលើគម្រោងវិនិយោគសាងសង់ស្ថានីយវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ និងគម្រោងវិនិយោគស្ថានីយអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ ០២កន្លែង នៅពោធិ៍សាត់០១កន្លែង ៦០MW និងនៅកំពង់ឆ្នាំង០១កន្លែង ៦០MW ដើម្បីផលិតអគ្គិសនីលក់ឲ្យអគ្គិសនីកម្ពុជា។<br>៣- សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសុខភាពសិក្សា។<br>៤- បញ្ហាផ្សេងៗ។ ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៤/០៤/១៩<br>**ម៉ោង០៩:០០នាទី** | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយសម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត។<br>២- សំណើសុំការពិនិត្យសម្រេចលើគម្រោងវិនិយោគសាងសង់ស្ថានីយវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ និងគម្រោងវិនិយោគស្ថានីយអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ០២កន្លែង នៅពោធិ៍សាត់០១កន្លែង ៦០MW និងនៅកំពង់ឆ្នាំង០១កន្លែង ៦០MW ដើម្បីផលិតអគ្គិសនីលក់ឲ្យអគ្គិសនីកម្ពុជា។<br>៣- សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសុខភាពសិក្សា។<br>៤- បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៤/០៤/១៩<br>**ម៉ោង១៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីជួបជុំពិសារអាហារសាមគ្គីជាមួយមហាគ្រួសារកីឡាកម្ពុជាលើកទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ។ |
| ៦ | ០៥/០៤/១៩<br>**ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត។<br>២- សំណើសុំការពិនិត្យសម្រេចលើគម្រោងវិនិយោគសាងសង់ស្ថានីយវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ និងគម្រោងវិនិយោគស្ថានីយអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ០២កន្លែង នៅពោធិ៍សាត់០១កន្លែង ៦០MW និងនៅកំពង់ឆ្នាំង០១កន្លែង ៦០MW ដើម្បីផលិតអគ្គិសនីលក់ឲ្យអគ្គិសនីកម្ពុជា។<br>៣- សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសុខភាពសិក្សា។<br>៤- បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

| | | |
|---|---|---|
| ៧ | **០៥/០៤/១៩ ម៉ោង១៥:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន យូណាន នៃសាធារណៈរដ្ឋប្រជាមានិតចិន នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | **០៨/០៤/១៩ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធជាផ្លូវការសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុព្រះស្រី-ល្ងសានវ៉ែន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ |
| ៩ | **០៨/០៤/១៩ ម៉ោង១៥:៣០នាទី** | ជួបសំណេះសំណាលជាមួយ ឯកឧត្តម **កយ បូរី** សមាជិកថ្មី នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | **០៩/០៤/១៩ ម៉ោង១៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីជួបជុំពិសារបាយសាមគ្គីរបស់សមាគមខ្មែរ-ចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលពិព័រណ៍កោះពេជ្រ។ |
| ១១ | **១០/០៤/១៩ ម៉ោង០៨:៣០នាទី** | ចូលរួមជាអធិបតី ក្នុងពិធីបើកសិក្ខាសាលានៃការផ្សព្វផ្សាយសមិទ្ធផលការងារ១០ឆ្នាំរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងការអនុវត្តកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅសណ្ឋាគារសុខាភ្នំពេញ។ |
| ១២ | **១០/០៤/១៩ ម៉ោង១៥:៣០នាទី** | ចូលរួមជាគណៈអធិបតី ក្នុងពិធីបិទសិក្ខាសាលានៃការផ្សព្វផ្សាយសមិទ្ធផលការងារ ១០ឆ្នាំ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងការអនុវត្តកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារសុខាភ្នំពេញ។ |
| ១៣ | **១១/០៤/១៩ ម៉ោង១៥:០០នាទី** | ចូលរួមអមជាកិត្តិយស ក្នុងពិធីសូត្រមន្ត ចម្រើនព្រះបរិត្ត និងពិធីជួបជុំហូបបាយសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងឱកាសអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | **២៣/០៤/១៩ ម៉ោង០៧:១៥នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជូនដល់និស្សិត នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្រោមអធិ-បតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ១៥ | **២៩/០៤/១៩ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំ ដើម្បីរៀបចំការងារត្រៀមសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ និងបញ្ហាផ្សេងៗ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| | | |
|---|---|---|
| ១៦ | ៣០/០៤/១៩<br>**ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារពាក់ព័ន្ធនឹងការរៀបចំសិក្ខាសាលាស្ដីពីការផ្សព្វផ្សាយសមិទ្ធផលការងារ១០ឆ្នាំ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងការអនុវត្តកម្មវិធីវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅទីស្ដីការ គណៈរដ្ឋមន្ត្រី។ |
| ១៧ | ៣០/០៤/១៩<br>**ម៉ោង១៨:៣០នាទី** | ចូលរួមក្នុងពិធីជប់លៀងជូនលោកជំទាវ **អោន សានស៊ូជី** ទីប្រឹក្សារដ្ឋនៃសាធារណៈរដ្ឋសហភាពមីយ៉ាន់ម៉ា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |
| **ល.រ** | **កាលបរិច្ឆេទ** | **សកម្មភាពក្នុងខែឧសភា ឆ្នាំ២០១៩** |
| ១ | ០១/០៥/១៩<br>**ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីពិសារអាហារ និងកំសាន្តសប្បាយជាមួយកម្មករនិយោជិកអបអរសាទរខួបលើកទី១៣៣ ទិវាពលកម្មអន្តរជាតិ ១ឧសភា ឆ្នាំ២០១៩ ក្រោមអធិ-បតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិឫស្សីស្រុក ឃុំឈើទាល ស្រុកគៀនស្វាយ ខេត្តកណ្ដាល។ |
| ២ | ០៤/០៥/១៩<br>**ម៉ោង០៨:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរខួបទី១៥៦ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ឧសភា ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិ-កោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ខេត្តតាកែវ និង**លោកជំទាវ** នៅសាលប្រជុំសាលាខេត្តតាកែវ។ |
| ៣ | ០៥/០៥/១៩<br>**ម៉ោង០៨:៣០នាទី** | ចូលរួមជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ នៃស្រុកព្រៃកប្បាស និងបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាស្រុកព្រៃកប្បាស នៅទីស្នាក់ការគណបក្សស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ៤ | ០៧/០៥/១៩<br>**ម៉ោង០៨:៣០នាទី** | ដឹកនាំក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្ដីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែត្រីមាសទី១ ឆ្នាំ២០១៩ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៧/០៥/១៩<br>**ម៉ោង១៦:៣០នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីពិសាអាហារស្រោយបួសខែរ៉ាម៉ាឌនឆ្នាំ២០១៩ នៃសាសនាឥស្លាមកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលពិព័រណ៍កោះពេជ្រ។ |
| ៦ | ០៩/០៥/១៩<br>**ម៉ោង១៨:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីជប់លៀងអបអរសាទរ Europe Day ជាមួយឯកអគ្គរាជទូតសហគមន៍អឺរ៉ុប នៅសណ្ឋាគារ Raffles Hotel Le Royal ។ |
| ៧ | ១៣/០៥/១៩<br>**ម៉ោង១៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីជប់លៀងជូនឯកឧត្តម ខេ ភី សាម៉ា អូលី នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសហព័ន្ធប្រជាធិបតេយ្យនេប៉ាល់ និង**លោកជំទាវ** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |

| | | |
|---|---|---|
| ៨ | **១៤/០៥/១៩ ម៉ោង១៥:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកវេទិកាធុរកិច្ច កម្ពុជា-នេប៉ាល់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម **ខេ គី សាម៉ា អូលី** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសហព័ន្ធប្រជាធិបតេយ្យនេប៉ាល់ នៅសណ្ឋាគារសុខាភ្នំពេញ។ |
| ៩ | **១៨/០៥/១៩ ម៉ោង០៨:០០នាទី** | ចូលរួមក្នុងពិធីបើកយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុម-ប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក អាណត្តិទី៣ របស់ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ១០ | **១៨/០៥/១៩ ម៉ោង១០:០០នាទី** | ចូលរួមក្នុងកិច្ចប្រជុំ ដើម្បីពិភាក្សាការងារចាំបាច់មួយចំនួនពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក អាណត្តិទី៣ របស់ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ១១ | **២២/០៥/១៩ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយសក្នុង ព្រះរាជពិធីច្រត់ព្រះនង្គ័ល និងទស្សនាពិព័រណ៍ផលិតផលកសិកម្ម សិប្បកម្មក្នុងស្រុក ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅទីព្រះស្រែ នៅភូមិត្រពាំងអង្គ សង្កាត់រកាក្រៅ ក្រុងដូនកែវ តាកែវ។ |
| ១២ | **២៧/០៥/១៩ ម៉ោង១៥:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយប្រតិភូសមាគមស្រាវជ្រាវសុខភាពចិន ដើម្បីអង្កេតស្វែងយល់អំពីធុរកិច្ច និងផ្លាស់ប្តូរសកម្មភាពគ្នា នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ១៣ | **២៩/០៥/១៩ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំ ដើម្បីពិភាក្សាការងារក្នុងការធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារចុះឃុំព្រៃល្វា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | **២៩/០៥/១៩ ម៉ោង១៥:០០នាទី** | ដឹកនាំកិច្ចប្រជុំ ដើម្បីពិភាក្សាការងារក្នុងការធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារចុះឃុំព្រៃកប្បាស នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | **៣០/០៥/១៩ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំ ដើម្បីពិភាក្សាការងារក្នុងការធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារចុះឃុំក្តាញ់ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | **៣០/០៥/១៩ ម៉ោង១១:០០នាទី** | ដឹកនាំកិច្ចប្រជុំ ដើម្បីពិភាក្សាការងារក្នុងការធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារចុះឃុំតាំងយ៉ាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | **៣០/០៥/១៩ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំ ដើម្បីពិភាក្សាការងារក្នុងការធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារចុះឃុំកំពង់រាប នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | **៣១/០៥/១៩ ម៉ោង១០:០០នាទី** | ដឹកនាំកិច្ចប្រជុំ ដើម្បីពិភាក្សាការងារក្នុងការធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារចុះឃុំអង្គាញ់ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ពិធីហូបនំបញ្ចុកគេជោសន្តិភាព ដើម្បីសាមគ្គីភាព និងឯកភាពជាតិ



នាព្រឹកថ្ងៃអាទិត្យ ៧កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៩ ឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស **យឹម ណុលឡា** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អនុប្រធានក្រុម-ការងារថ្នាក់ជាតិចុះជួយខេត្តតាកែវ និងជាសហប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយស្រុកព្រៃកប្បាស និងលោកជំទាវ **ហ៊ីង សុបញ្ញា** បានចូលរួមក្នុងពិធីហូបនំបញ្ចុកគេជោសន្តិភាព ដើម្បីសាមគ្គីភាព និងឯកភាពជាតិ នៅតាមឃុំមួយចំនួននៃស្រុកព្រៃកប្បាស ខេត្តតាកែវ តបតាមការអំពាវនាវប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្ហាញអំពីការសាមគ្គីជាតិ មិនមែនជាការបំបែកបំបាក់ជាតិនោះទេ ខណៈក្រុមប្រឆាំងបានយកនំបញ្ចុកមកញុះញង់បំបែកបំបាក់ជាតិខ្មែរដែលកំពុងតែរស់នៅក្នុងសុខសន្តិភាព និងការអភិវឌ្ឍ។

នៅក្នុងឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី **យឹម ណុលឡា** បានមានប្រសាសន៍ឱ្យដឹងថា ការរៀបចំពិធីហូបនំបញ្ចុកជួបជុំគ្នានៅថ្ងៃនេះ គឺដើម្បីបង្ហាញឱ្យឃើញអំពីការសាមគ្គីភាពជាតិរវាងមហាគ្រួសារខ្មែរយើងទាំងមូល ខ្មែរមិនមានការបែកបាក់ជាតិដូចការលើកឡើងរបស់ក្រុមណាមួយនោះទេ។ តែផ្ទុយទៅវិញ ប្រជា-ពលរដ្ឋខ្មែរយើងចេះរួបរួមសាមគ្គីគ្នាជាធ្លុងមួយជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីរក្សាសន្តិភាព និងការអភិវឌ្ឍប្រទេសឱ្យកាន់តែរីកចម្រើនខ្លាំងឡើងថែមទៀត និងប្រែក្លាយនំបញ្ចុកទៅជាអត្តសញ្ញាណរបស់ជាតិ មិនមែនជាអត្តសញ្ញាណរបស់បក្សនយោបាយណាមួយឡើយ។



ឯកឧត្តមទេសរដ្ឋមន្ត្រី បានរំលឹកអំពីការគិតគូររបស់ប្រមុខថ្នាក់ដឹកនាំដែលតែងតែបានប្រកាសអំពីគោលនយោ-បាយរាជរដ្ឋាភិបាល គោលនយោ-បាយជាតិគាំពារសង្គមចំពោះបងប្អូនកម្មករ កម្មការិនី និងគិតគូរពីសុខទុក្ខរបស់បងប្អូនប្រជាពល-រដ្ឋ ដោយមិនប្រកាន់ពណ៌សម្បុរ ជាតិសាសន៍ ឬនិន្នាការនយោបាយនោះឡើយ។

ក្នុងនាមជាសមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាមួយរូប ឯកឧត្តមទេសរដ្ឋមន្ត្រី បានប្តេជ្ញាខិតខំយកចិត្តទុកដាក់ដល់ការរស់នៅប្រចាំថ្ងៃ សុខទុក្ខ និងដោះស្រាយការលំបាកទាំងឡាយរបស់បងប្អូន៕

## ពន្យល់ពាក្យ

**វប្បធម៌ :**

វប្បធម៌ < វប្ប + ធម៌

វប្ប : ការសាបព្រោះ ការបណ្ដុះពូជ...។

ធម៌ : សភាវៈទ្រទ្រង់សត្វលោក សភាព ធម្មជាតិ ច្បាប់ ហេតុ...។

វប្បធម៌ : ការផ្សាំបណ្ដុះចំណេះវិជ្ជា និងប្រាជ្ញាស្មារតីឲ្យបានលូតលាស់ ចម្រើនដោយវិទ្យាសាស្ត្រ ឬដោយសិល្បៈផ្សេងៗជាដើម។ (វចនានុក្រមខ្មែរ ពុទ្ធសាសនបណ្ឌិត្យ)

ខ្លះថា វប្បធម៌ គឺអ្វីៗដែលទាក់ទងនឹងការសិក្សា ការអប់រំ។

ខ្លះថា វប្បធម៌ គឺអ្វីៗដែលធ្វើឲ្យមានការរីកចម្រើនគ្រប់វិស័យ។

រួមមក វប្បធម៌ គឺធម៌ទាំងឡាយដែលបណ្ដុះបណ្ដាលសេចក្ដីចម្រើន និងឧត្ដមគតិខ្ពង់ខ្ពស់របស់មនុស្សជាតិ តាមចំណេះដឹង តាមការសិក្សាអប់រំ ច្បាប់ ទំនៀមទម្លាប់ ឬតាមសិល្បៈ ភាសា និងអក្សរដែលជាគ្រឿងប្រដាប់សម្រាប់អធិប្បាយផ្សាយ។ (កេង វ៉ាន់សាក់)

**សង្គមធម៌ :**

សង្គមធម៌ < សង្គម + ធម៌

សង្គម : ការរួមប្រជុំមនុស្សជាក្រុម ដោយមានអង្គការចាត់តាំងត្រឹមត្រូវ។

ធម៌ : សភាវៈទ្រទ្រង់សត្វលោក សភាព ធម្មជាតិ ច្បាប់ ហេតុ...។
ទ្រឹស្ដីឆ្ពោះទៅរកអនុវត្តន៍យ៉ាងសកម្ម។ (សរ សារុន)

សង្គមធម៌ គឺជាធម៌ទាំងឡាយដែលទ្រទ្រង់ការរស់នៅរបស់មនុស្ស ហើយនឹងបណ្ដុះសេចក្ដីសុខសប្បាយរបស់មនុស្សជាតិ តាមគ្រឿងសម្ភារៈ ប្រដាប់ប្រើប្រាស់ វិធីបច្ចេកទេសបង្កើតផលិតផល ឬតាមវិធីរៀបចំសង្គមមនុស្សដូចជា សេដ្ឋកិច្ច សង្គមកិច្ច នយោបាយ ឬតាមស្ថាប័នផ្សេងៗ។ (កេង វ៉ាន់សាក់)

**អរិយធម៌ :**

អរិយធម៌ < អរិយ + ធម៌

អរិយៈ : ប្រសើរ ត្រឹមត្រូវ សុភាព រៀបរយ មានបែបបទល្អ ស្លូតត្រង់ ដែលឥតទោស។

ធម៌ : សភាវៈទ្រទ្រង់សត្វលោក សភាព ធម្មជាតិ ច្បាប់ ហេតុ...។

អរិយធម៌ :

- ធម៌ដែលនាំឲ្យកើតសេចក្ដីសុខចម្រើន
- ធម៌របស់អរិយជន
- សណ្ដាប់ធ្នាប់ បែបបទរៀបរយ។ (វចនានុក្រមខ្មែរ ពុទ្ធសាសនបណ្ឌិត្យ)

ខ្លះថា អរិយធម៌ គឺជាធម៌ទាំងឡាយណា ដែលជាសភាព និងតម្លៃនៃការលូតលាស់ដុះដាលរីកចម្រើនខ្ពង់ខ្ពស់ ថ្លៃថ្នូរក្នុងការរស់នៅរបស់មនុស្សក្នុងសង្គម ដែលប្រកបទៅដោយរបៀបរៀបរយ គ្រឿងប្រដាប់ប្រើប្រាស់គ្រប់គ្រាន់ ជំនឿ ចំណេះដឹង ចំណង់ចំណូលចិត្តគ្រប់បែបយ៉ាងក្នុងគោលដៅស្វែងរកសុខៈ។ (អរិយធម៌ខ្មែរ - អ្នកស្រី ត្រឹង ងា)

ខ្លះថា អរិយធម៌ គឺសម្គាល់យកការចម្រើនលូតលាស់នៃជនជាតិណាមួយ ដែលផ្ទុយនឹងសភាពព្រៃផ្សៃ។ ទស្សនៈនេះសម្អាងលើការរីកចម្រើនលូតលាស់លើវិស័យវិទ្យាសាស្ត្របច្ចេកទេស របៀបរៀបចំប្រទេស និងច្បាប់ទម្លាប់ដ៏ត្រឹមត្រូវនៃជនជាតិណាមួយ។ (វប្បធម៌ និងអរិយធម៌ខ្មែរ - សរ សារុន)

ខ្លះថា អរិយធម៌ គឺជាកម្រងនៃមែកធាងច្រើនបែបយ៉ាងក្នុងសង្គមដែលមានលក្ខណៈជា សាសនា សីលធម៌ សិល្បៈ វិទ្យាសាស្ត្របច្ចេកទេស មានជីវិតអាចបន្តគ្នាក្នុងកាលអាកាស ហើយជាលក្ខណៈរួមរបស់សង្គមណាមួយ ឬសង្គមចំនួនច្រើនដែលទាក់ទងគ្នា។ (វប្បធម៌ និងអរិយធម៌ខ្មែរ - សរ សារុន)

## មែកធាងនៃអរិយធម៌

- អរិយធម៌
  - វប្បធម៌
    - ចំណេះដឹង
      - ជំនឿ
      - សីលធម៌ គុណធម៌
      - លទ្ធិ សាសនា
      - ទស្សនវិជ្ជា វិទ្យាសាស្ត្រ
      - បច្ចេកវិទ្យា
    - កំណាត់ផ្សាយ
      - ភាសា អក្សរ សញ្ញា
      - អក្សរសាស្ត្រ អក្សរសិល្ប៍
      - សិល្បៈ ពត៌មាន
    - អនុវត្តន៍
      - ទំនៀមទម្លាប់ ប្រពៃណី
      - ការសិក្សាអប់រំ
      - កីឡា ល្បែង ច្បាប់
  - សង្គមធម៌
    - គ្រឿងសង្គម
      - ប្រដាប់រស់នៅ
      - ប្រដាប់តិចនិក
      - វិជ្ជាជីវៈ
    - របបសង្គម
      - សេដ្ឋកិច្ច
      - សង្គមកិច្ច
      - នយោបាយ
    - ទម្រង់សង្គម
      - ស្ទូលសង្គម
      - វណ្ណៈសង្គម
      - អង្គការសង្គម

**ចំណាំ៖**

វប្បធម៌(គេប្រើតែឯង) = ចំណេះដឹងរបស់មនុស្សម្នាក់ៗ ពីវិជ្ជាក្តី ពីជីវភាពក្តី ពីព្រឹត្តិការណ៍ណាមួយក្តី។

វប្បធម៌ - អរិយធម៌
- → វប្បធម៌ = ការលូតលាស់ផ្លូវចិត្ត
- → អរិយធម៌ = ការលូតលាស់ផ្លូវសម្ភារៈ

អរិយធម៌(គេប្រើតែឯង) = ក្តោបយកទាំងវប្បធម៌ទាំងសង្គមធម៌។

អរិយធម៌ខ្មែរ - សូ មុយឃៀង ទិត សៀង ជា ឈិន

# កម្លាំងសាមគ្គីខ្មែរសម័យអង្គរ (តចប់)

សិលាចារឹកពី Preah Ngôk ក្នុងរជ្ជកាលព្រះបាទឧទយាទិត្យវរ្ម័នទី២ ប្រាប់យើងថា ឧត្តមសេនីយ៍សង្គ្រាមបាននាំមកនូវមាសពេជ្រកែវកងពីភូមិភាគដែលខ្លួនវាយយកបានពីពួកប្រឆាំងនឹងរាជបល្ល័ង្កមកថ្វាយចំពោះអាត្មន៍ដ៏ពិសិដ្ឋរបស់ព្រះរាជាដែលជាឥស្វរសិវៈ (Isvara Siva) ស្ថិតនៅក្នុងព្រះសិវលិង្គធ្វើអំពីមាសនេះសឲ្យឃើញទៀតថា អ្វីដែលគេថ្វាយចំពោះព្រះរាជា គឺថ្វាយចំពោះព្រះសិវៈហ្នឹងឯង។ សិលាចារឹកនៅប្រទេសខ្មែរបានប្រាប់យើងថា ព្រះសិវលិង្គដែលតំណាងលិទ្ធិទេវរាជារបស់ព្រះបាទជ័យវរ្ម័នទី២ ហើយដែលបានប្រតិស្ឋានក្នុងប្រាសាទព្រះអារាមរោងចិន លើភ្នំគូលែន (មហេន្ទ្របវ៌ត) ត្រូវបានបន្តបន្ទាប់គ្នាយកទៅតម្កល់ក្នុងប្រាសាទលើភ្នំធម្មតា ឬលើភ្នំដែលមនុស្សស្ថាបនាឡើងដើម្បីគោរពបូជា។ ព្រះសិវលិង្គនេះក្លាយទៅជានិមិត្តរូបពិសេសរបស់រាជាណាចក្រ។ ព្រះរាជាអង្គណាមានព្រះសិវលិង្គនោះឯង ទើបជាព្រះរាជាពេញលក្ខណៈច្បាប់។

ក្នុងករណីដែលមានសង្គ្រាមដណ្តើមរាជ្យគ្នា យើងឃើញថាបេក្ខជនមួយអង្គៗ ដើម្បីរាជបល័ង្កបានប្រាប់ប្រជាពលរដ្ឋថា ខ្លួនជាព្រះរាជាពេញលក្ខណៈច្បាប់ ដោយសម្អាងថា ព្រះសិវលិង្គដំបូងដែលជាទេវរាជានៅក្នុងរាជវាំងរបស់ខ្លួន បើទោះណាព្រះទេវរាជនោះជាព្រះសិវលិង្គសាងឡើងដោយខ្លួនឯងក៏ដោយ។ នៅពេលដែលព្រះបាទយសោវរ្ម័នទី១ យាងចូលទិវង្គតទៅ ព្រះបាទជ័យវរ្ម័នទី៤ មានរាជវាំងនៅឯលិង្គបុរៈ (កោះកេរ នៅចំងាយ៧០ គ.ម. ទិសឦសានក្រុងអង្គរ) ជ្រែករាជ្យក្នុងគ.ស.៩២១ ហើយមានឥសានម៉ុរ៌តិ (Isanamurti) ជាព្រាហ្មណ៍បុរោហិត ដើម្បីធ្វើពិធីគោរពបូជាចំពោះព្រះទេវរាជា។ នៅឯយសោធរបុរៈ (អង្គរ) ព្រះបាទហស៌វរ្ម័នទី១ នៅគ្រងរាជ្យ ហើយមានព្រាហ្មណ៍ឈ្មោះ កុមារស្វាមិ (Kumarasvami) ជាអ្នកបម្រើព្រះទេវរាជា។ តាមពិតព្រះបាទហស៌វរ្ម័នទី១ ជាព្រះរាជាពេញលក្ខណៈច្បាប់ ព្រោះព្រះអង្គជារាជបុត្រនៃព្រះបាទយសោវរ្ម័នទី១ ហើយព្រះទេវរាជានោះទៀតក៏ប្រហែលជាព្រះទេវរាជាពិតប្រាកដ ដែលព្រះអង្គបានទទួលពីព្រះបិតាមក។ ការសម្អាងទៅលើព្រះទេវរាជារៀងខ្លួន គឺដើម្បីប្រមូលប្រជាជនមកខាងខ្លួន គឺដើម្បីសុំកម្លាំងសាមគ្គីនិងការគាំទ្រពីប្រជាពលរដ្ឋ ក្នុងកិច្ចប្រតិបត្តិការផ្សេងៗរបស់ខ្លួន ឬដើម្បីប្រមូលប្រជាជនមកខាងខ្លួន។

ក្នុងសិលាចារឹកខ្លះ ហាក់ដូចជាចង់ប្រាប់យើងថា ព្រះរាជាជំនាន់ក្រោយអាចសាងព្រះសិវលិង្គតំណាងព្រះទេវរាជាបានដែរ។ ព្រះបាទឧទយាទិត្យវរ្ម័នទី២ (១០៥០-១០៦៦) បានសាងភ្នំមួយអំពីមាស សាងប្រាសាទមាសមួយលើភ្នំនោះ ហើយតម្កល់ព្រះសិវលិង្គធ្វើពីមាសក្នុងប្រាសាទនោះ។ សិលាចារឹកជាភាសាសំស្ក្រឹតនៅលង្វែក បានបញ្ជាក់សេចក្តីនេះយ៉ាងច្បាស់លាស់។ ប្រាសាទមាសក្នុងទីនេះ គឺសំដៅដល់ប្រាសាទបាពួន ដែលជាផ្ចិតនៃទីក្រុងអង្គរទី២ ។

លទ្ធិព្រះទេវរាជាប្រហែលជាមានគេគោរព ក្នុងប្រទេសជាច្រើនក្នុងអាស៊ីភាគអាគ្នេយ៍។ នៅចម្ប៉ាមហាឫសីភ្គុ (Bhrgu) បានរៀបពិធីគោរពព្រះទេវរាជាដើម្បីព្រះបាទឧរូជៈ (Uroja) ដែលជាការផ្តើមសន្តិវង្សនៅឥន្ទ្របុរៈ(Indrapura) ប្រទេសចម្ប៉ាក្នុងគ.ស. ៨៧៥។

មហាឫសីអគ្គសត្យៈ(Agastya) ក៏បានរៀបចំពិធីដូចខាងលើនេះដែរនៅហ្សាវ៉ា(Java) ក្នុងគ.ស. ៧៦០។

សិលាចារឹកជាភាសាសំស្ក្រឹតនៅឯទួលគុកប្រាសាទ (Tuol Kuk Prasat) ស្រុកសម្បូរ ខេត្តក្រចេះ បានប្រើពាក្យព្រះកម្រតេងជគតរាជ្យ (Vrah Kammraten Jagattaraja) ក្នុងពេលមុនរាជាភិសេកព្រះបាទជ័យវរ្ម័នទី២ទៀតផង តែនៅក្នុងរជ្ជកាលព្រះអង្គប៉ុណ្ណោះ។ យើងបានរៀបរាប់មកខាងលើនេះ ដើម្បីបញ្ជាក់ថាស្តេចអង្គនោះ បានសោយរាជ្យជាច្រើនឆ្នាំមុនពិធីរាជាភិសេក។

លទ្ធិព្រះទេវរាជាប្រហែលត្រូវបានគេគោរពនៅចម្ប៉ា ក្នុងចំណែកទី២នៃសតវត្សទី៤នៃគ.ស. នៅក្នុងរជ្ជកាលព្រះបាទភទ្រវរ្ម័ន(គ.ស. ៣៤៩-៣៩០) សិលាចារឹកនៅមីសឺន(Mi Sơn) បានប្រាប់យើងថា ភទ្រេស្វរៈជាទេវៈចម្បងដែលគេគោរពនៅប្រទេសចម្ប៉ា ជាទេវៈសម្រាប់ជនជាតិចាម។ ក្នុងករណីនេះយើងឃើញថាគេភ្ជាប់ព្រះនាមព្រះរាជា ទៅនឹងព្រនាមរបស់ព្រះទេវៈថា ភទ្រឥស្វរៈ = ភទ្រេស្វរៈផងដែរ។ ភទ្រេស្វរៈជាព្រះនាមនៃព្រះសិវលិង្គដែលគេដែលគោរពនៅវត្តភូ (លិង្គបវ៌ត) Vat Phu (Lingaparvata) ហើយដែលប្រហែលជាគេយកព្រះនាមនេះមកពីចម្ប៉ាំង ក្នុងពេលដែលខ្មែរធ្វើចម្បាំងឈ្នះចាមនៅក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ ឬក៏ក្នុងបុរាណកាលនៃជាតិទាំងពីរគេគោរពទេវៈនេះដូចគ្នា។ ព្រះបាទរាជេន្ទ្រវរ្ម័នបានថ្វាយព្រះនាមព្រះសិវលិង្គជាព្រះទេវរាជារបស់ខ្លួនថា រាជេន្ទ្រស្រ្វរៈ ហើយបានតម្កល់ក្នុងប្រាសាទមេបុណ្យខាងកើតក្នុងគ.ស. ៩៥២។ ក្នុងសិលាចារឹកនៅប្រាសាទនាងខ្មៅ(គ.ស.៦៧៨-៦៨៧) និងទួលអ្នកតាបាក់ក បានឲ្យដឹងថា នៅមុនសម័យអង្គរ គេឃើញមានព្រះនាមព្រះសិវលិង្គមួយហៅថា បុស្កេស្វរៈ។ ក្នុងសិលាចារឹកនៅប្រាសាទព្រះធាតុក្វាន់ពីរ(គ.ស.៧១៦) ហើយដែលបានកសាងឡើងដោយព្រះបាទបុស្ករាក្ស ដែលជាព្រះញាតិវង្សនៃក្សត្រពាលាទិត្យ ដែលបានគ្រងរាជ្យនៅអនិន្ទិតបុរៈ ព្រះអង្គបានយាងទៅសោយរាជ្យនៅសម្ភុបុរៈ (គ.ស.៧២៣)។ ឯកសារមួយក្រោយសតវត្សទី៩ បានប្រាប់យើងថា បុស្ករាក្សនេះត្រូវជាបងប្អូនជីដូនមួយព្រះបាទជ័យវរ្ម័នទី២។ ក្នុងករណីនេះ តើយើងយល់ថាលទ្ធិព្រះទេវរាជាត្រូវបានព្រះបាទជ័យវរ្ម័នទី២ ចម្លងមកពីប្រទេសជ្វា ឬគ្រាន់តែបន្តទំនៀមទម្លាប់ដែលមានរួចហើយស្រាប់នៅក្នុងប្រទេសខ្មែរ?

សន្តិវង្សសៃលេន្ទ្រដែលគ្រប់គ្រងកោះហ្សាវ៉ា ស៊ូម៉ាត្រា និងជ្រោយម៉ាឡាយូតាំងពីសតវត្សទី៨ ដល់សតវត្សទី១២នៃគ.ស. មានការទាក់ទងជាប់ជានិច្ចទៅនឹងលទ្ធិព្រះទេវរាជា ហើយគេសាងប្រាសាទសម្រាប់ព្រះទេវរាជានៅលើភ្នំធម្មតា ឬធ្វើដោយមនុស្សដូចជានៅឯប្រទេសខ្មែរ។ ឬពុំនោះសោតទេ លទ្ធិព្រះទេវរាជាបាននាំចូលមកពីប្រទេសចម្ប៉ា?

នៅប្រទេសស្រីលង្កា នៅសតវត្សទី៥នៃគ.ស. ព្រះបាទកស្សបទី១ (គ.ស.៤៧៧-៤៩៥) បានសាងប្រាសាទនៅលើភ្នំសិគិរី(Sigiri) ក្នុងភាគខាងជើងប្រទេសស្រីលង្កា ដើម្បីជាលំនៅនៃព្រះទេវរាជា។ តែព្រះទេវរាជានេះពុំមែនជាព្រះសិវលិង្គទេ គឺព្រះរាជាអង្គនោះឯងដែលគង់នៅក្នុងប្រាសាទនោះ។ នៅប្រទេសឥណ្ឌាវិធីបូជាយញ្ញឈ្មោះ អស្វមេធ ប្រមូលយកនូវមហិទ្ធិរិទ្ធព្រះរាជា ដើម្បីធ្វើសង្គ្រាមពង្រីកទឹកដី។ នេះក៏មានទំនងប្រហែលគ្នានឹងពិធីរៀបចំលទ្ធិទេវរាជា ដើម្បីឲ្យព្រះរាជាទៅជាស្ដេចចក្រពត្តិមានអំណាចនៅក្នុងទិសទាំងបួន។

មកដល់រជ្ជកាលព្រះបាទ សូរ្យវរ្ម័នទី២ លទ្ធិទេវរាជាក៏នៅជាលទ្ធិសម្រាប់រដ្ឋ។ តែដោយហេតុថាក្សត្រអង្គនេះជាអ្នកគោរពព្រះវិស្ណុ ក៏ព្រះអង្គបន្ថែមលទ្ធិមួយទៀតហៅថា លទ្ធិគោរពព្រះវិស្ណុរាជា ដូចមានភស្តុតាងនៅប្រាសាទអង្គរវត្ត ដែលជាលំនៅនៃព្រះវិស្ណុរាជ គឺព្រះបាទសូរ្យវរ្ម័នទី២ ហ្នឹងឯង។

ព្រះបាទជ័យវរ្ម័នទី៧ ដែលជាអ្នកគោរពព្រះពុទ្ធសាសនាមហាយាន ក៏បានបន្ថែមលទ្ធិមួយទៀតហៅថា លទ្ធិគោរពព្រះពុទ្ធរាជា ដោយបានសាងប្រាសាទបាយ័នជាលំនៅនៃព្រះពុទ្ធរាជាទាំងមានឆ្លាក់ព្រះភ័ក្ត្រធំៗនៃព្រះពោធិសត្វអវលោកេស្វរៈ បែរទៅគ្រប់ទិសទាំងបួន។

យើងបានពិចារណាដោយមានភស្តុតាងគ្រប់គ្រាន់ឃើញថា លទ្ធិទាំងបីនេះ : ទេវរាជា វិស្ណុរាជា និងពុទ្ធរាជា នៅពេលដែលគេបានរៀបចំពិធីប្រកក់ប្រសិទ្ធិថ្មី បានជំរុញទឹកចិត្តខ្មែរឲ្យសាមគ្គីយ៉ាងមាំ ក្នុងការរៀបចំប្រទេស ទាំងក្នុងការធ្វើសង្គ្រាមពង្រីកទឹកដីនៅសម័យនោះ។ មិនត្រឹមតែប៉ុណ្ណោះ ប្រាសាទល្អៗហើយធំស្កឹមស្កៃជាច្រើន ក៏ត្រូវបានគេស្ថាបនាឡើងដើម្បីលទ្ធិទាំងនេះដែរ ដូចមានជាអាទិ៍ ប្រាសាទបាគងជា

វិហារសម្រាប់ព្រះទេវរាជា នៃព្រះបាទឥន្ទ្រវរ្ម័នទី១ ប្រាសាទភ្នំបាខែង ជាវិហារភ្នំសម្រាប់ព្រះទេវរាជានៃព្រះបាទយសោវរ្ម័នទី១ ប្រាសាទមេបុណ្យនិងប្រាសាទប្រែរូប ជាលំនៅព្រះទេវរាជានៃព្រះបាទរាជេន្ទ្រវរ្ម័នទី២ ប្រាសាទអង្គរវត្តជាលំនៅសម្រាប់ព្រះវិស្ណុរាជានៃព្រះបាទសូរ្យវរ្ម័នទី២ ប្រាសាទបាយ័នអង្គរធំជាលំនៅសម្រាប់ព្រះពុទ្ធរាជារបស់ព្រះបាទជ័យវរ្ម័នទី៧។

ហេតុបានជាសាមគ្គីដ៏ខ្លាំងក្លារបស់ខ្មែរ ទៅជាទន់ខ្សោយនៅសម័យក្រោយ?

មិនត្រឹមតែសម័យក្រោយសតវត្សទី១៣នៃគ.ស.ហើយ ដែលសាមគ្គីខ្មែរទៅជាចុះទន់ខ្សោយ សូម្បីតែក្នុងសម័យមុនក៏យើងបានជួបប្រទះដែរ គឺក្នុងរជ្ជកាលណាដែលលទ្ធិនេះ មិនបានគេគោរពជិតដល់។ កត្តាដែលនាំឲ្យសាមគ្គីខ្មែរចុះខ្សោយដុនដាប ប្រហែលជាបណ្តាលមកពី៖

១-អយុត្តិធម៌ក្នុងសង្គមនៅសម័យខ្លះ

២-នៅសតវត្សទី១៤ សង្គ្រាមបានកើតឡើងជាញឹកញយជាមួយនឹងសៀមបណ្តាលឲ្យក្សត្រខ្មែរដែលគ្រងរាជ្យធ្វេសប្រហែស ព្រងើយកន្តើយនឹងលទ្ធិទេវរាជា ឬវិស្ណុរាជា ឬពុទ្ធរាជា ជាហេតុធ្វើឲ្យទន់ខ្សោយនូវជំនឿរបស់ប្រជាពលរដ្ឋ។

៣-ប្រតិកម្មមួយដ៏សាហាវកកើតឡើង គឺប្រជាពលរដ្ឋលែងទទួលស្គាល់ព្រះរាជាថា ជាព្រះសិវៈ ឬព្រះវិស្ណុ ឬព្រះពុទ្ធ៕



**<u>គំនិតគួរចងចាំ :</u>**

" ការពិតរបស់ប្រវត្តិសាស្ត្រតែងតែមានការស្រពិចស្រពិល និងផ្តល់ឧទាហរណ៍ពុំចេះអស់ ត្បិតមានប្រភពចេញពីមនុស្ស "

( A. Aron Introduction à la philosophie de l'histoire )។

ដោយបណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

## ជាខ្មែរ !

(បទពាក្យ៩)

យើងជាខ្មែរមានពូជពង្សវង្សប្រាកដ
រាប់សតវត្សលើផែនដីកម្ពុជា
អារ្យធម៌របស់ខ្មែរមានយូរយារ
ពុំមែនជាពូជសាសន៍ដែលឥតមូលដ្ឋាន។
មើលអង្គរក្រុមប្រាសាទរបស់ខ្មែរ
គឺជាកេរសក្ខីភាពបញ្ជាក់បាន
នូវថាមភាពសាមគ្គីភាពក្លាហាន
ក្ដីក្សេមក្សាន្តនៃដូនតាយើងជាខ្មែរ។
ប្រវត្តិយើងជាប្រវត្តិសុខចិត្តកាយ
រស់សប្បាយជាមួយគ្នាមកហូរហែ
ស្ដេចមន្ត្រីរាស្ត្រប្រជាគ្មានបែកបែរ
រក្សាថៃគ្នារៀងមកជាធម្មតា។
សុខដូចនេះក៏ព្រោះតែមិនលោភលន់
មិនបានប្លន់គេប្រវញ្ចកាញ់លើគ្នា
ធំឬតូចមានឬក្រតាមធម្មតា
តាមវាសនាតាមផលាកិច្ចការផ្ដល់។
បើកុំតែជាតិសាសន៍គេមកឈ្លានពាន
សមយើងបានសុខរហូតមិនមានយល់
ការបែកបាក់ធ្លាក់ធ្លោយថ្លស់អស់ឥទ្ធិពល
រហូតដល់សឹងតែភ្លេចកំណើតដើម។
តែឥឡូវក្ដីអាស្រូវវិនាសបង់
ដោយរឹទ្ធិវង្គគេជោសែនបានដណ្ដើម
សិទ្ធិសេរីន័យជីវិតជាដង្ហើម
ឲ្យខ្មែរផ្ដើមរស់ជាថ្មីលើដីកេរ។៕

*សួនកំណាព្យ-បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ថុង*

## កង្វល់អ្នកអក្សរសាស្ត្រ

(បទពាក្យ៧)

អ្នកផងមើលអ្នកអក្សរសាស្ត្រ
ឃើញ"ប្រាថ"ផ្ដេសផ្ដាសគ្មានបានការ
រៀបរាប់មេឃាខែភ្លឺថ្លា
ប្រហែលចិន្តារាយតាមខ្យល់។
តាមពិតអ្នកផងមើលមិនធ្លុះ
ចិត្តក្នុងពោះពុះទុក្ខកង្វល់
ភ័យខ្លាចលោកនេះដើរមិនដល់
គោលដៅដែលយល់ក្នុងគំនិត។
គំនិតដែលបានពីការវែក
វិភាគបំបែកក្រោយពិនិត្យ
ជញ្ជឹងរឿងរ៉ាវជីវិតពិត
មិនមែនប្រឌិតរាយតាមខ្យល់។

*សួនកំណាព្យ-បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ថុង*

## ចោរឡើមធំ

កាលនោះ ប្រធានភូមិមួយនៅសហករណ៍គាស់ក្រឡ ខេត្តបាត់ដំបង មានឫកពាក្រអឺតក្រទម កាចសាហាវណាស់ ភ្នែកគាត់ឡើងក្រហម។ យប់មួយសមមិត្តប្រធានបើកអង្គប្រជុំក្រោមដើមព្រីងពីមុខផ្ទះគាត់ ដើម្បីពង្រឹងការងារសតិអារម្មណ៍ គាត់បានលើកឡើងថា:

- មិត្តយើង មិនត្រូវមានដៃមានជើង ដើរលួចបេះបោចដំណាំរួមទេ។ ដូចអង្គការយើងបញ្ជាក់ច្បាស់លាស់ហើយថា " បើយើងមានហូបគឺហូបទាំងអស់គ្នា បើអត់គឺអត់ទាំងអស់គ្នា "។

បន្ទាប់ពីគាត់បានបឺតបារីស្លឹកសង្កែចេញភ្លើងពណ៌ក្រហមប៉ុនមេដៃរួច ក៏ពោលបន្តថា:

- មិត្តយើងណាទម្លាប់រពិសដៃជើង មិនទាន់ជម្រុះចោលត្រូវប្រយ័ត្នឲ្យមែនទែន កង់ប្រវត្តិសាស្ត្រវិលទៅមុខជាប់ជានិច្ច មិត្តណាលូកដៃដាច់ដៃលូកជើងដាច់ជើង។ ជាក់ស្តែងពោតចម្ការភូមិយើងនៅតាមព្រំរបង អស់ផ្លែរលីងសល់តែសំបកជាប់ដើមតែប៉ុននោះ។ មិត្តណាប្រព្រឹត្តប្រសិនបើអង្គការរកឃើញ មិត្តយើងដឹងថាធ្វើយ៉ាងម៉េចទេ ?

នារីម្នាក់អង្គុយផ្អែកសសរផ្ទះសមមិត្តប្រធានភូមិ ស្រវាបានស្នូលពោតមួយ ស្ទុះងើបឡើង រួចស្រែកថា:

- ត្រូវតែកំទេចចោល អាចោរឡើមធំ ព្រោះវាហ៊ានក្បត់សមូហភាព។
- និយាយចប់នារីនោះកាច់បំបាក់ស្នូលពោតទាំងស្រដីថា: គឺកំទេចអញ្ចឹង!

តាមពិតទៅស្នូលពោតមាននៅក្បែរសសរផ្ទះសមមិត្តប្រធានភូមិរដូករណែលទៀតឯណោះ៕

ចំណាំ :

- ទោសខ្លួនឯងមើលមិនយល់
- ហាមគ្រាប់តាមអង្គការ តែត្រូវធ្វើតាមបញ្ជាអង្គការដាក់ចុះ

*អក្សរសិល្ប៍ប្រជាប្រិយខ្មែរ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចឹង*

## ផ្ទាំងស្មោរល្មៅ

គ្រាមួយនោះ នងនិងនុតជាមន្ត្រីក្រមការ ដើរតាមផ្លូវជាមួយគ្នាដើម្បីទៅទារពន្ធនៅភូមិមួយ ក៏បានជួបនឹងចម្ការមួយ នុតស្រែកថា: យី! ល្មៅចម្ការនេះធំៗដល់ហើយ!

- នងនិយាយកាត់ភ្លាមៗថា: ល្មៅប៉ុនហ្នឹងធំអី ពីថ្ងៃមុនអញឃើញល្មៅមួយធំប៉ុនខ្ទមនោះ:
- នុតសម្លឹងមុខនង ហើយពោលថា: ថ្ងៃមុនអញបានឃើញផ្ទាំងមួយប៉ុនសាលាឃុំ!
- នងក៏ពោលចំអកឲ្យនុតថា: ឆ្កួត! វាមិនដែលមានផ្ទាំងអីធំដល់ម្លឹងៗទេ។
- នុតញញឹមហើយស្រដីតបទៅវិញថា: ផ្ទាំងហ្នឹង! ទុកស្មោរល្មៅដែលឯងឃើញនោះហើយ។
- នង: ?!?!

ចំណាំ :

- អំណួតឬបំផ្លើស ចូលបទកុហក
- ពាក្យច្រើនភូត ច្រើនចាញ់អាត្មា

*អក្សរសិល្ប៍ប្រជាប្រិយខ្មែរ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចឹង*

## យល់ដឹងពីវដ្តជីវិតសត្វផ្សោតទន្លេមេគង្គ



ផ្សោតទន្លេមេគង្គក៏ដូចជាសត្វផ្សោតដទៃទៀតដែរ គឺជាថនិកសត្វទឹក( សត្វមានឈាមក្តៅ ដកដង្ហើម បង្កើតកូន និងចិញ្ចឹមកូនដោយទឹកដោះ) ដែលករ-កំណើតតាំងពីសម័យកាលស័កទី៣ ប្រហែល ៦៥ លានឆ្នាំទៅ១,៨លានឆ្នាំមុន គ.ស. ដែលគេតែងប្រទះឃើញរស់នៅក្នុងតំបន់សមុទ្រទឹករាក់ តំបន់ទឹកភ្លៀវ និងទឹកសាប ដែលមានល្បាយតាមតំបន់ឆ្នេរ ចាប់ពីឆ្នេរខាងកើតប្រទេសឥណ្ឌា រហូតមកដល់ឈូងសមុទ្រថៃ និងសមុទ្រចិនខាងត្បូងក្នុងតំបន់ឆ្នេរប្រទេសហ្វីលីពីន និងនៅក្នុងទន្លេទឹកសាបចំនួន ៣ គឺ៖ ទន្លេ



អ៊ីរ៉ាវ៉ាឌី ប្រទេសភូមា ទន្លេមេគង្គ ប្រទេសកម្ពុជា និងទន្លេមហាខាំ ក្នុងតំបន់កាលីម៉ាន់កាន់នៃកោះប័រណេអូ ប្រទេសឥណ្ឌូណេស៊ី។ ជាទូទៅពពួកសត្វផ្សោតទាំងអស់ពុំសូវទទួល បានការចាប់អារម្មណ៍នៅក្នុងវិទ្យា-សាស្ត្រប៉ុន្មានទេ ព្រោះពួកវាមិននៅក្នុងឧស្សាហកម្មចំណីអាហារដូចមច្ឆាជាតិឡើយ។ ផ្សោតនេះត្រូវបានអ្នកវិទ្យាសាស្ត្រ ឃើញជាដំបូងនៅអំឡុងឆ្នាំ១៨៦៦ នៅទន្លេអ៊ីរ៉ាវ៉ាឌី (Irrawadi) បច្ចុប្បន្នហៅថា អាយេ-យ៉ាវ៉ាឌី (Ayeyarwadi) ប្រទេសមីយ៉ាន់ម៉ា ដោយកំណត់ឈ្មោះវិទ្យាសាស្ត្រថា Orcaella brevirostris (Owen in Gray, 1866) តាមភិនភាគថានានិច្ច័យសាស្ត្រ (Taxonomy) ដូចខាងក្រោម៖

- រជ្ជៈ (Kingdom): Animalia
  - អំបូរ (Phylum): Chordata
    - សន្តាន (Class): Mammalia
      - លំដាប់ (Order): Cetacea
        - ពូជ (Family): Delphinidae
          - ពួក (Genus): Orcaella
            - ប្រភេទ (Species): O. brevirostris (ភាសា ឡាតាំង មានន័យថា ចំពុះខ្លី ឬមាត់ខ្លី)

សត្វផ្សោតប្រភេទនេះ ត្រូវបានគេហៅឈ្មោះខុសៗគ្នាទៅតាមតំបន់ដែលវារស់នៅ ដូចជា អ៊ីរ៉ាវ៉ាឌី-ដូហ្វីន (ឈ្មោះដែលនិយមហៅជាទូទៅតាមអ្នកវិទ្យាសាស្ត្រដែលឃើញដំបូង) ភាសាខ្មែរហៅថា ផ្សោត ភាសាឡាវហៅថា ផាកា ភាសាថៃហៅថា ប៉ាឡូម៉ាហួបាត មានន័យថាផ្សោតក្បាលត្រងោល ។

ផ្សោតនេះមានទំនាក់ទំនងហ្សេណេទិក (Genetic) យ៉ាងជិតស្និទ្ធិទៅនឹងបាឡែន Killer whale (orca)។ ជាទូទៅវាមានពណ៌ប្រផេះនៅផ្នែកខាងខ្នង និងពណ៌ព្រលែតនៅផ្នែកពោះ មានព្រុយខ្នងតូចរាងមូលនៅក្រោមពាក់កណ្តាលខ្នង។ ថ្ងាសខាងមុខរាងខ្ពស់ហើយមូលនិងគ្មានចំពុះ។ ព្រុយចំហៀងសងខាងរាងធំហើយមូល។ ផ្សោតពេញវ័យមានប្រវែងជាង២ម៉ែត្រ ទម្ងន់ប្រហែលជាង១០០គ.ក្រ។ តាមកំណត់ត្រានៃប្រទេសថៃបានឲ្យដឹងថា ផ្សោតធំបំផុតដែលប្រទះឃើញមានប្រវែង២,៧៥ម៉ែត្រ ជាផ្សោតឈ្មោលទម្ងន់ជាង១០០គ.ក្រ ក៏ប៉ុន្តែក៏មានការប្រទះ ឃើញផ្សោតឈ្មោលមួយក្បាលស្លាប់នៅក្នុងទន្លេមេគង្គម្តុំខាងលើកោះផ្តៅ ស្រុកសំបូរ ខេត្តក្រចេះ ប្រទេសកម្ពុជា ក្នុងអំឡុងឆ្នាំ១៩៩៨ មានប្រវែង២,៨០ម៉ែត្រ ទម្ងន់១៤០គ.ក្រ (កំណត់ត្រារបស់អ្នកនិពន្ធ)។

ដោយសារទើបតែមានការចាប់អារម្មណ៍ដល់ប្រភេទសត្វបាឡែន និងផ្សោតនៅក្រោយសង្គ្រាមលោកលើកទីពីរនោះ ការស្រាវជ្រាវវិទ្យាសាស្ត្រត្រូវបានដឹកនាំធ្វើនៅក្នុងកំរិតមួយដែលអាចផ្តល់ការយល់ដឹងពីលក្ខណៈជីវសាស្ត្រខ្លះៗរបស់ពួកវាសម្រាប់ចាត់ចែងរៀបចំកិច្ចអភិរក្ស ជាពិសេសចំពោះសត្វបាឡែនដែលគេធ្វើនេសាទឲ្យបានសមរម្យ។ ចំពោះផ្សោតប្រភេទនេះ គេគ្រាន់តែអាចដឹងថា ពួកវាធ្វើទំនាក់ទំនងគ្នាដោយការបញ្ចេញសម្លេងជញ្ជក់មាត់ ធ្វើសំឡេងង៉ែតង៉ុតៗ និងធ្វើសំឡេងដូចពពែ ឬរងាវនៅក្នុងកម្រិតប្រេកង់ខ្លាំងប្រហែល៦០គីឡូហឺត្ស សម្រាប់បញ្ជាក់ទីតាំងនិងសកម្មភាព។ ត្រី ពងត្រី ពពួកមឹក បង្គា ក្តាម សុទ្ធតែជាចំណីផ្សោតទាំងអស់។ ផ្សោតពេញវ័យអាចបន្តពូជពង្សបាននៅពេលមានវ័យក្នុងចន្លោះអាយុពី៧ទៅ៩ឆ្នាំ ដែលមានប្រវែងប្រហែលពីរម៉ែត្រ ទម្ងន់ប្រហែល៧០-៨០គ.ក្រ។ មានព័ត៌មានខុសគ្នាជាច្រើនទាក់ទងទៅនឹងការបន្តពូជពង្សរបស់ផ្សោតនេះ អ្នកខ្លះថាផ្សោតដោយមេដោយឈ្មោលនៅក្នុងចន្លោះខែធ្នូ និងខែមិថុនា ហើយផ្សោតមេពពោះរយៈកាល១៤ខែទើបបង្កើតកូនថែមទាំងចំណាយពេលបំបៅនិងបណ្តើរកូនអស់រយៈពេល១៥-១៨ខែទៀត។ ខ្លះទៀតថាការដោយមេដោយឈ្មោលរបស់ផ្សោតអាចកើតឡើងគ្រប់ពេលពេញមួយឆ្នាំ។

ក្នុងអំឡុងទសវត្ស៩០ ផ្សោតទន្លេមេគង្គបានក្លាយជាប្រធានបទអភិរក្សដើម្បីអភិវឌ្ឍអេកូទេសចរណ៍ដែលត្រូវជំរុញឲ្យមានការស្រាវជ្រាវទាក់ទងស៊ីជំរៅទៅនឹងប្រវត្តិវដ្តជីវិត លក្ខណៈជីវសាស្ត្រ និងទម្លាប់របស់វា។ ព័ត៌មានវិទ្យាសាស្ត្រពាក់ព័ន្ធ ព័ត៌មានដែលប្រមូលបានពីអ្នកស្រុក និងការសង្កេតដោយកត់ត្រាតាមវិធីសាស្ត្រវិទ្យាសាស្ត្រត្រូវបានយកមកវិភាគដើម្បីកំណត់លក្ខណ្ឌធម្មជាតិនៃផ្សោតទន្លេមេគង្គ។ ផ្សោតត្រូវបានពលរដ្ឋខ្មែរ ជាពិសេសអ្នករស់នៅតាមដងទន្លេស្គាល់យ៉ាងច្បាស់ ដែលយ៉ាងហោចណាស់ក៏មានចម្លាក់រូបផ្សោតមួយក្នុងចំណោមត្រីជាច្រើននៅជញ្ជាំងខាងលិចប្រាសាទបាយ័នជាសក្ខីកម្មផងដែរ។ ភាពសម្បូរបែបនៃត្រីទឹកសាបនៅក្នុងប្រព័ន្ធទន្លេមេគង្គតាំងពីជាងបួនពាន់ឆ្នាំមុនបានទាក់ទាញហ្វូងផ្សោតឲ្យធ្វើបន្លាស់ទីពីសមុទ្រចូលមករស់នៅយ៉ាងសុខដុម។ រហូតមកដល់ចុងទសវត្ស៩០ ទម្លាប់ផ្សោតតែងចូលទៅស៊ីចំណី(ត្រី) នៅក្នុងបឹងទន្លេសាបនៅរដូវវស្សា ហើយមួយចំនួនពិសេសផ្សោតពេញវ័យ និងផ្សោតចំណាស់បានវិលត្រឡប់ទៅជំរកនៅតំបន់ទឹកជ្រៅនៃមេគង្គលើនៅដើមរដូវប្រាំង(ខែតុលា-ធ្នូ)។ ផ្សោតពេញវ័យអាចបន្តពូជពង្សបានចាប់ពីអាយុ៧-៨ឆ្នាំ(ទម្ងន់ប្រហែល៧០-៨០គ.ក្រ)ដល់២៣-២៥ឆ្នាំ(ទម្ងន់ជាង១០០គ.ក្រ)។ រដូវដោយមេដោយឈ្មោលមានពីរដងក្នុងមួយឆ្នាំ គឺអំឡុងខែមករា-កុម្ភៈ និងខែកក្កដា-សីហា ដោយការសម្គាល់ឃើញផ្សោតទាំងគូរៗដែលប្រែព័ណពីប្រផេះទៅជាខ្មៅហែលទៅមកនៅជាមួយគ្នាអស់រយៈកាលប្រហែលមួយខែទើបបែកគ្នា។ ផ្សោតបង្កើតកូននៅអំឡុងខែវិច្ឆិកា-ធ្នូ និងខែឧសភា-មិថុនា។ នៅជិតដល់

ពេលផ្សោតមេទម្លាក់កូនតែងតែឃើញមានផ្សោតមេមួយក្បាលទៀតហែបហែលជាប់ជាមួយគ្នា ដើម្បីត្រៀមជួយទ្រកូនផ្សោតដែលទើបនឹងកើតមកលើផ្ទៃទឹកដកដង្ហើម។ នៅពេលទម្លាក់កូន ផ្សោតមេ និងកូនដែលទើបនឹងកើតប្រែព៌ណពីប្រផេះទៅជាខ្មៅភ្លាមៗ ហើយផ្សោតទាំងហ្វូងបានចូលមករួមហែបហែលជាមួយគ្នាចេញពីកន្លែងដែលទម្លាក់កូនទៅទីទឹកជ្រៅ រួចទើបបែកគ្នា។ កូនផ្សោតទើបនឹងកើតមានប្រវែងប្រហែល ១ម៉ែត្រ ឯទម្ងន់មានប្រហែល ៦-១១គ.ក្រ អាស្រ័យទៅតាមទំហំមេផ្សោត។ ផ្សោតមេនិងកូនដែលទើបកើតនេះប្រែព៌ណទៅជាប្រផេះវិញ នៅរយៈពេលមួយខែក្រោយមក។ ផ្សោតមេបណ្តើរ និងថែទាំកូនរយៈពេល ១៥-១៨ខែ ហើយកូនផ្សោតបៅដោះមេទាំងស្រុងរយៈពេល៤-៥ខែដំបូងដោយមានផ្សោតមេមួយក្បាលតាមជួយទ្រកូនឲ្យបៅដោះមេវាជារហូត។ ផ្សោតមេបង្ហាត់កូនដែលឈប់បៅអាយុ៩ខែ ឲ្យចេះហែលទឹកបង្វិលខ្លួនដោយខ្លួនឯង ក្នុងការត្របាក់ត្រីជាចំណីនៅកន្លែងទឹកវាក់ក្បែរច្រាំងទន្លេរៀងរាល់ល្ងាច អស់រយៈពេលប្រហែលមួយខែ។ ចាប់ពីអាយុ៦ខែឡើងទៅ កូនផ្សោតអាចហែលបានដោយខ្លួនឯងខ្លះ អាចចាប់ត្រីជាចំណីខ្លះ ហើយបន្ថយការបៅដោះបន្តិចម្តងៗរហូតដល់មេឈប់បណ្តើរ ហើយផ្សោតមេដែលជួយក៏បែកចេញនៅពេលនោះដែរ។ នៅរដូវវស្សា ផ្សោតបានប្រែពីពណ៌ប្រផេះទៅជាព៌ណឃ្មៀចទៅតាមពណ៌ទឹកដែលល្អក់ ហើយប្រែជាប្រផេះវិញនៅរដូវប្រាំង។

ផ្សោតស្ទាវ(អាយុ៣-៨ឆ្នាំ)មានទម្លាប់ដេញស៊ីត្រីជាហ្វូងដោយភាពរហ័សរហួនខ្លាំងក្លានៅពេលហ្វូងត្រីធ្វើបន្លាស់ទី(ត្រីធំៗ ត្រូវផ្សោតខាំត្របាក់ដាច់មួយកំណាត់ខាងកន្ទុយ នៅសល់តែកំណាត់ខាងក្បាលនៃត្រីពោធិ ត្រីប្រា ត្រីតានេល ត្រីខ្យា ត្រីឆ្លាំង ត្រីក្លាំងហាយ ត្រីកេសជាដើម ដែលត្រូវអ្នកនេសាទរើសបានពីក្រោយហ្វូងផ្សោត)។ ធ្មេញផ្សោតចាប់ជ្រុះពីអាយុ១៥ឆ្នាំឡើងទៅរហូតដល់អស់នៅអាយុ២៣-២៥ឆ្នាំ ដូច្នេះផ្សោតចាស់ៗ ត្រូវបង្ខំចិត្តនៅឆ្ងាយពីហ្វូងពួកស្ទាវ និងត្រូវទ្រាំត្របាក់លេបត្រីតូចៗជាអាហារ។ ផ្សោតអស់លទ្ធភាពបន្តពូជពង្សនៅអាយុប្រហែល២៣-២៥ឆ្នាំ។ ផ្សោតអាចរស់បានដល់អាយុ៣០ឆ្នាំ។

ការអង្កេតនៅរយៈកាលចុងក្រោយនេះបានឲ្យដឹងថា ផ្សោតដែលរស់នៅសឹងតែជាប្រចាំនៅតាមជម្រកទាំងបួន (អ្នកស្រុកនិយមហៅថាអន្លង់ផ្សោតដែលមានទីតាំងនៅក្នុងកំណាត់ទន្លេប្រវែង ២០០គ.ម នៃតំបន់ទឹកជួរខាងក្រោមល្បាក់ខោន) មានចំនួនថយចុះគួរឲ្យបារម្ភ បើប្រៀបធៀបទៅនឹងការបង្ហាញខ្លួនរបស់ពួកវានៅស្ទើរទូទាំងប្រព័ន្ធទឹកសាបកម្ពុជាកាលពីទសវត្សឆ្នាំ៦០ ៧០ និង៨០។ ក្តីកង្វល់អំពីការធ្លាក់ចុះចំនួនផ្សោតទន្លេមេគង្គដ៏កម្រនេះ ត្រូវបានរាជរដ្ឋាភិបាលដាក់ចុះនូវវិធានការអភិរក្ស តាមការបង្កើតគណៈកម្មការអភិរក្សនិងអភិវឌ្ឍតំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គនៅឆ្នាំ២០០៦ ដើម្បីស្រាវជ្រាវលក្ខខណ្ឌជីវសាស្រ្តនិងមូលហេតុនៃការស្លាប់របស់ផ្សោត ហើយស្វែងរកដំណោះស្រាយសមស្របដែលអាចធានាចីរភាពរបស់វាសម្រាប់ការអភិវឌ្ឍអេកូទេសចរណ៍។ ការប្រឹងប្រែងរបស់គណៈកម្មការ ហើយក្រោយមករដ្ឋបាលជលផលព្រមជាមួយការចូលរួមសហប្រតិបត្តិការរបស់អង្គការមូលនិធិសត្វព្រៃពិភពលោក(WWF) ក្នុងកិច្ចអភិរក្សសត្វផ្សោតបានទទួលលទ្ធផលគួរឲ្យទុកចិត្តបាន ដោយចំនួនផ្សោតមានការកើនឡើងពី៦០ក្បាលនៅទសវត្សឆ្នាំ៩០ មកប្រហែលជិតមួយរយក្បាលនាបច្ចុប្បន្ននេះ។

ទោះជាយ៉ាងនេះក៏ដោយ ការថយចុះផលស្តុកត្រីនិងការកើនឡើងនៃការនេសាទខុសច្បាប់ក្នុងតំបន់ជម្រកផ្សោត នៅតែជាការគំរាមកំហែងមួយដល់សត្វផ្សោត ហើយអនាគតនៃការអភិវឌ្ឍវារីអគ្គិសនីនៅលើដងទន្លេមេគង្គ ប្រសិនបើមាននោះ ក៏អាចជាការប៉ះពាល់ដល់ទម្លាប់រស់នៅរបស់ផ្សោតផងដែរ។ ដូច្នេះការត្រៀមលក្ខណៈធ្វើការចិញ្ចឹម ភ្ញាស់ បង្កាត់សិប្បនិម្មិតកម្ម និងការបង្កើតជម្រកធម្មជាតិថ្មីសម្រាប់ផ្សោតនៅមុនពេលផលប៉ះពាល់ខាងលើកើតឡើង អាចជាវិធានការអភិរក្សដើម្បីធានានិរន្តរភាពសត្វផ្សោត អេកូទេសចរណ៍ និងសង្គម-សេដ្ឋកិច្ចដ៏មានប្រសិទ្ធភាពបំផុត៕

*ដោយ ទូច ស៊ាងតាណា*

# ប្រសាសន៍ពេជ្រ

" ខ្មែរមានកិត្តិយសរបស់ខ្មែរ ខ្មែរត្រូវការជំនួយ តែខ្មែរក៏ត្រូវការកិត្តិយសរបស់ខ្មែរដែរ។ "

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

(មន្ទីរពេទ្យមង្គលបុរី ខេត្តបន្ទាយមានជ័យ ១៥ មិថុនា ២០០៦)


ក្រុមការងារព្រឹត្តិបត្រ

នាយកគ្រប់គ្រង:
យឹម ណុលសន

និពន្ធនាយក:
អ៊ុំ ថុង

និពន្ធនាយករង:
អ៊ុន វ៉ាល់ឡឺរ៍
ប៉ិច សុខា

ការិយាល័យនិពន្ធ:
នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត
លី គឹមសុខ
ឆយ អូន
ប៊ុន ណារិទ្ធ
កែវ វិចិត្រ
សួង លាងហៃ
អ៊ុច ចោងសេង
ញឹក កោសល្យវិទ្យា
ទូច ស៊ាងតាណា
ប៉ែន សារឿន
រ័ត្ន សណ្តាប់
ទូច ចាន់ធី
លឿង ស៊ីម៉ូណា
សរ សុគន្ធីតា
ម៉ម សារិទ្ធ
ស៊ាង សុជល្លា

អ្នកចាត់ចែងផលិត:
អ៊ុន វ៉ាល់ឡឺរ៍
រ័ត្ន សណ្តាប់

អ្នកចែកផ្សាយ:
អេង រត្នមុនី
សំ សំណាង
សេក វុទ្ធី

ការីកុំព្យូទ័រ:
សយ វាស្នា
យឹម ច័ន្ទតារា


## មាតិកា

**ទំព័រ**


I- អារម្ភកថា ១

II- បទអត្ថាធិប្បាយ " ទស្សនាទាននៃការអភិវឌ្ឍន៍ប្រភពថាមពលកកើតឡើងវិញនៅកម្ពុជា ស្ថានីយវារីអគ្គិសនីនិងស្ថានីយអគ្គិសនីពន្លឺព្រះអាទិត្យ" ២-៦

III- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត

១- សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត ៧-៨

២- សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (Law on E-Commerce) ៩

៣- សិក្ខាសាលាស្តីពីការផ្សព្វផ្សាយសមិទ្ធផលការងារ១០ឆ្នាំរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងការអនុវត្តកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ១០-១៤

IV- ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំត្រីមាសទី១ឆ្នាំ២០១៩ ១៥-២១

V- កម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ២២-២៦

VI- សកម្មភាពផ្សេងៗរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ២៧-៣៤

VII- នាទីវប្បធម៌

- ពន្យល់ពាក្យ ( វប្បធម៌ - សង្គមធម៌ - អរិយធម៌ ) ៣៥-៣៦
- កម្លាំងសាមគ្គីខ្មែរសម័យអង្គរ (តចប់) ៣៧-៣៩

VIII- នាទីកំណាព្យ

- ជាខ្មែរ (បទពាក្យ៩) ៤០
- កង្វល់អ្នកអក្សរសាស្ត្រ (បទពាក្យ៧) ៤០

IX- នាទីកំសាន្ត

- ផ្ទាំងស្មោរល្ងៅ ៤១
- ចោរថ្លើមធំ ៤១

X- ពីនេះពីនោះ

- យល់ដឹងពីវដ្តជីវិតសត្វផ្សោតទន្លេមេគង្គ ៤២-៤៤



រូបភាពក្នុងកិច្ចប្រជុំវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា